## ការសម្ភាសរបស់លោកពូកែវ សឿន

អ្នកដែលសម្ភាសន៍ឈ្មោះញែមសុគន្ធា អ្នកដែលត្រូវគេសំភាសន៍ឈ្មោះកែវសឿន

**ការសង្ខេបរបស់លោកពូកែវ សឿន**

លោកពូកែវ សឿន គាត់ជាអ្នកមកពីស្រុកតាកែវ ហើយគាត់រត់នៅទីនោះតាំងតែពីធំដឹងក្តីមកទឹមតែមករស់នៅភ្នំពេញហ្នឹងឥឡូវ៥ឆ្នាំទេ ព្រោះកូនអោយមកមើលចៅ ហើយក៏បានផ្លាស់ទីលំនៅទៅ!!លោកពូជាកូនអ្នកកសិករហើយក្រុមគ្រួសារគឺបានប្រកបរបរនេះដើម្បីចិញ្ចឹមជីវិតហើយលក់ស្រូវដើម្បីទិញម្ហូប ស្រុកកំណើតគាត់គឺនៅជិតទល់ដែនប្រទេសវៀតណាម ។ លោកពូបានកើតទាន់ពេលរបបសង្គ្រាម ប៉ុល ពតហើយនឹងលន់ នល់ លោកពូត្រូវរត់គេខ្លួនចូលក្នុងត្រង់សេពេលគ្រាប់បែកទំលាក់មកម្តងៗ ហើយក្នុងរបបប៉ុល ពតគាត់បានធ្វើការនៅក្នុងកងចល័ត ហើយការហូបចុកគឺពិបាកខ្លាំងបំផុត គឺបបរទឹកឡើងរាវ ហើយបើបេះបន្លែថែមគឺថាបើមេកងស្រួលមិនអីទេតែបើមិនស្រួលគឺត្រូវគេយកទៅកសាង ហើយលោកពូបានស្លាប់សាច់ញាតិនៅក្នុងរបបហ្នឹងផងដែរ លោកពូបាននិយាយថាការធ្វើការមានសភាពមួយដែលសាហាវណាស់មេកងគឺជាមនុស្សដែលងាយធ្វើបាបអ្នកដទៃកាប់សម្លាប់ធ្វើខុសតែបន្តិចបន្តួចគឺយកទៅកសាងហើយ ហើយកសាងហ្នឹងគឺមនុស្សតែងតែបាត់ខ្លួនលែងត្រលប់មកវិញ ។គាត់ធ្វើការច្រើនហើយបានហូបអាហារដែលមិនគ្រប់គ្រាន់ហើយគេងក៏បានតិចទៀតត្រូវងើបពីយប់ដើម្បីធ្វើការបើមិនធ្វើតាមទេគឺត្រូវគេយកទៅសម្លាប់ចោលដែរ គាត់ថាគឺជីវិតរបស់មនុស្សម្នាក់ៗនៅពេលហ្នឹងគឺគួរអោយអានិតហើយវាពិបាកណាស់។ សព្វថ្ងៃលោកពូរស់នៅជាមួយកូនប្រពន្ធ នឹងចៅដោយមានសុភមង្គល ហើយគាត់តែងតែប្រដៅកូនអោយក្លាយជាមនុស្សល្អជានិច្ច។

ក៖
ជំបូងនិងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូឲ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់លោកពូនិងសូមជំរាបសួរដល់លោកពូដែរលោកពូអញ្ចឹងនាងខ្ញុំឈ្មោះនាងសុគន្ធាជាអ្នកសម្ភាសអំពីជីវិតរបស់

លោកពូនៅក្នុងថ្ងៃនេះពួកយើងសម្ភាសន៍នៅក្នុងថ្ងៃទី 23 ខែឧសភាឆ្នាំ 2018 មានទីតាំងស្ថិតនៅក្នុងភូមិ លោកពូថាភូមិអ្វីដែរឬទេ?

ខ៖ ត្រពាំងជ្រៃ។

កៈ លោកពូអាចជម្រាបភូមិឃុំស្រុកខេត្តខណ្ឌទាំងអស់បានដែរឬទេលោកពូ?

ខ៖ នៅទីនេះខ្ញុំមិនសូវស្គាល់ប៉ុន្មានទេពីព្រោះខ្ញុំមកពីតាកែវ។

កៈ អញ្ចឹងលោកពូមកពីស្រុកតាកែវទេមែនទេ?

ខ៖ បាទបាទ!!

មិត្តភក្តិ៖ នៅភូមិត្រពាំងជ្រៃ!!

ខ៖ ភូមិត្រពាំងជ្រៃ សង្កាត់អ្វីទេដូចជាពោធិ៍សែនជ័យ!!

កៈ សង្កាត់ពោធិ៍សែនជ័យខណ្ឌសែនសុខហើយមែនទេលោកពូ?

ខ៖ បាទបាទ។

កៈ ខណ្ឌសែនសុខរាជធានីភ្នំពេញប្រទេសកម្ពុជា។

ខ៖ បាទ!!!

កៈ ចានៅទីហ្នឹង លោកពូបានមកធ្វើការឲ្យឱ្យផ្ទះរបស់លោកពូខ្ញុំ អញ្ចឹងទៅក៏ចៃដន្យជួបលោកពូក៏សុំការសម្ភាសន៍ពីលោកពូៗចឹងទៅលោកពូណោះ??

ខ៖ បាទបាទ!!

កៈ អញ្ចឹងលោកពូសូមជម្រាបឈ្មោះរបស់លោកពូពេញណាស់ទាំងត្រកូលរបស់លោកពូ!!

ខ៖ បាទខ្ញុំឈ្មោះកែវសឿន។

កៈ កែវសឿន!!

ខ៖ បាទ!!

កៈ សម្រាប់លោកពូកែវសឿនឆ្នាំនេះលោកពូអាយុប៉ុន្មានហើយ ?

ខ៖ ខ្ញុំប្រហែលជា58 ឆ្នាំហើយ

កៈ ចាំឆ្នាំខ្មែរគឺជាឆ្នាំអ្វីដែលលោកពូ?

ខៈ ខ្ញុំកើតមិនដឹងជាឆ្នាំឆ្នាំប៉ុន្មានទេនេះចាំជូត!!50ឆ្នាំជាង!!

កៈ ហ្នឹងហើយអូនរបស់ម្ដាយខ្ញុំ 2 ឆ្នាំ ។

ខៈ ម្ដាយកើតឆ្នាំអ្វីដែល?

កៈ ម្ដាយរបស់ខ្ញុំកើតឆ្នាំចត្រូវហើយ។

ខៈ ខ្ញុំ 58 ឆ្នាំហើយ។

កៈ លោកពូសម្រាប់លោកពូមានឈ្មោះហៅខាងក្រៅទេឪពុកដែល??

ខៈ អត់មានទេមានឈ្មោះតែមួយនឹងទេ!!

កៈ អត់មានអ្នកណាគេដាក់ងារឲ្យគេមែនទេ? ដូចថានៅខ្មែរយើងជាច្រើនដាក់ងារឲ្យអញ្ចឹងទៅណាស់!!

ខៈ បាទបាទ។

កៈ មនុស្ស 1 នាក់មានឈ្មោះរហូតទៅដល់ 3 ឬក៏បួនឥវ៉ាន់នោះ!!!

ខៈ តាំងពីកំណើតមកមានឈ្មោះតែមួយនឹង!!!

កៈ ចាំចាំលោកពូសម្រាប់លោកពូមានថ្ងៃខែឆ្នាំកំណើតលោកពូកើតនៅថ្ងៃទីខែឆ្នាំណាដែលលោកពូ?

ខៈ ទេមិនបានចាំទេ!!

កៈ តែដឹងតែសព្វថ្ងៃនិងមានអាយុ 58 ឆ្នាំនៅក្នុងឆ្នាំ 2018។

ខៈ 58 ឆ្នាំហើយ។

កៈ ខ្ញុំគិតថាលោកពូកើតឆ្នាំ 1960 ដោយសារម្ដាយរបស់ខ្ញុំក៏កើតនៅក្នុងឆ្នាំ 1958 គាត់បងរបស់លោកពូពីឆ្នាំនោះ!!

ខៈ បាទបាទ!!!

កៈ ចឹងលោកពូ 1960 ហើយបើសិនជាគិតទៅនោះ!!! លោកពូទីកន្លែងកំណើតរបស់លោកពូនៅឯណាដែលលោកពូ ប្រាប់តាំងពីឃុំភូមិឃុំខេត្តស្រុក?

ខៈ ភូមិកំណើតរបស់ខ្ញុំនៅភូមិដើមចាន់ ឃុំរមិញស្រុក កោះអណ្តែតខេត្តតាកែវ។

កៈ ការនៅជិតព្រំប្រទល់វៀតណាមដែរឬទេលោកពូនៅទីនោះ?

ខៈ នៅនឹងព្រំប្រទល់វៀតណាមនិង។

កៈ នៅជាប់គ្នាតែម្តងលោកពូមែនទេ?

ខៈ បាទនៅជាប់!!ស្រុកកោះអណ្តែតជាប់តែម្តង។

កៈ ចាំ លោកពូមានដែលធ្លាប់ចេញចូលប្រទេសវៀតណាមអីដែរឬទេ?

ខៈ កាលពីខ្ញុំនៅស្រុកចេញចូលដែលនៅកាលពេលជំនាន់ 79 ពេលដែល មកដល់87 88 មានអីទៅទិញអង្ករទៅទិញបន្លែ ទៅទិញអ្វីពីស្រុកគេមកហូប បាទបាទ!!!

កៈ ប៉ុន្តែមួយទៀតសុំសួរដល់លោកពូពេលជំនាន់ប៉ុលពតលោកពូនៅជិតព្រំដែនប្រទេសវៀតណាមឬក៏លោកពូគេជម្លៀសមកពីណា?ទៅទីណាវិញ?

ខៈ កាលពីជំនាន់ប៉ុលពតគេជម្លៀសញ៉ុមមកនៅខេត្តកំពង់ស្ពឺឯណា!!

កៈ អាវលោកពូមិនព្រមពេលហ្នឹងបើដឹងនៅស្រុកខ្មែរវេទនាអញ្ចឹងមិនព្រមរត់ចូលទៅក្នុងទឹកដីវៀតណាមតែម្តងទៅមិនរួចខ្លួនកើតលោកពូ?

ខៈ កាលពីពេលនិងខ្លះគេរត់ចូលទៅរស់ទៅទៀតថាវៀតណាមធ្វើបាបធ្វើអ្វីខ្លះទៅណាស់ខ្លះធ្វើបាបខ្លះអត់ទៅខ្លាហូសខ្លាក៏ស្លាប់ទៅបាត់អញ្ចឹងទៅ!!

កៈ ឯទោះជាយ៉ាងណាក៏គ្រាន់បើដែរមែនទេ?

ខ៖ លោកពូរបស់ខ្ញុំម្នាក់គាត់ទៅពេលទៅនឹងគាត់ស្លាប់ដោយគាត់នៅរស់លោកពូម្នាក់គេចាប់ដាក់គុកដែរនៅពេលជំនាន់និងពេលយើងរត់ចូលយើងហើយនិងប្រទេសវៀតណាមមិនសត្រូវគ្នា!!!

ក៖ ហ្ហូមែន!!!

ខ៖បាទ!!

ក៖បើ ចូលប្រទេសថៃបានរួចខ្លួនដែរទើបប្រទេសថៃអត់រួចទេ!!

ខ៖ បើប្រទេសថៃមិនអីទេ !!! ពេលនឹងគេឃើញយើងគេចាប់ដាក់គុកគេមិនអោយយើងរស់ទេព្រោះយើងជាសត្រូវរបស់គេកំណត់វាគឺបែបហ្នឹង!!តាំងពីជីដូនជីតាមក!!

ក៖មែននឹងហើយពូថាប្រទេសខ្មែរនិងប្រទេសវៀតណាមមិនដែលសូវត្រូវគ្នាប៉ុន្មានទេថាវាមានបញ្ហាផ្ទៃក្នុងច្រើនណាស់ដែលយើងមិនដឹងអស់មិនដឹងការពិតអញ្ចឹងទៅលោកពូណាស់!!

ខ៖ បាទ!!

ក៖ អារឿងនយោបាយគេយ៉ាងមិច ប៉ុន្តែមិនបាច់និយាយទាក់ទងនឹងរឿងនយោបាយទេ!!

ខ៖ បាទពីរឿងនយោបាយ!!!

ក៖ ពីជីវិតរបស់លោកពូវិញតើលោកពូមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែល?

ខ៖ ខ្ញុំមានបងប្អូន 5 នាក់។

ក៖ ស្រីប៉ុន្មានប្រភេទតែដែលលោកពូ?

ខ៖ ស្រី 3ប្រុស 2!!

ក៖ ចាឥឡូវលោកពូកគាត់នៅរស់ទាំងអស់ឬក៏មានខ្លះអនិច្ចកម្មទៅហើយ?

ខ៖ នៅប្អូន 1 ពិការជើងទាំង 2 នឹងធ្វើកងទ័ព!!

ក៖ កងទ័ព?

ខ៖ ធ្វើកងទ័ពទ័ពសម្តេចនាយកហ៊ុនសែនវិធ្វើតាំងពីឆ្នាំ 1987 ឆ្នាំ 1987 គាត់ចូលធ្វើ។

ក៖ ចាំអញ្ចឹងពេលមុនគាត់ជើងគាត់ដំបូងគាត់មិនអីទេមែនទេលោកពូ?

ខ៖ អត់អីទេធ្វើទ័ពប៉ុន្តែជាន់មីនដាច់!!

ក៖ ដាច់តជើងទាំងពីរ?

ខ៖ បាទដាច់!!!

ក៖ អូយមិនដឹងគាត់ឈឺប៉ុណ្ណាពិបាកប៉ុណ្ណាទេលោកពូ?

ខ៖ ឥឡូវក៏នៅតែនៅស៊ីប្រាក់ខែប្រាក់ខែគេមួយខែបាន400000។

ក៖ ហ្ហ៎ បាននិយាយទៅគេជួយដែរ!!

ខ៖ គេជួយ!!

ក៖ ហោងហើយអ្នកខ្លះវិញធ្វើទ័ពដែរប៉ុន្តែគេអត់ជួយខ្ញុំឆ្ងល់ណាស់លោកពូដាច់ដៃដាច់ជើងពីការដែរតើ!!

ខ៖បន្តែបើបងប្អូនខ្ញុំបងប្អូនខ្ញុំមួយជីដូនមួយគាត់ធ្វើទ័ពដែលគាត់ចេញទៅចេញតាំងពីឆ្នាំ70(1970)ការជើងម្ខាងដែរប៉ុន្តែអត់មានប្រាក់ខែកងទ័ពខ្មែរក្រហម។

ក៖ ហ្ហ៎!! ទ័ពខ្មែរក្រហម។

ខ៖ ទ័ពខ្មែរក្រហមតែបើពួកយើងវៃចាញ់គេគេចាប់បានគេហៅឈ្លើយសឹកហើយគេលែងហៅទ័ពទៀតហើយអត់មានប្រាក់ខែហ្វបទេ។

ក៖ ចាំ! អញ្ចឹងលោកពូពេលគាត់ភ្លាមមានប្រាប់ពីពេលដែលគាត់មានភ្លាមយ៉ាងម៉េចដែរលោកពូគាត់មានដែលប្រាប់លោកពូថាយ៉ាងម៉េចយ៉ាងម៉េចដែរឬទេ?អំពីព្រឹត្តិការណ៍ដែលគាត់ត្រូវមីននឹងណាស់?

ខ៖ អូនរបស់ខ្ញុំអាកំបុតជើងពីរនឹងមែនទេ?

ក៖ ហ្នឹងហើយនឹងហើយ!!!

ខ៖ គាត់ជាន់មីននៅយើងនេះនៅភ្នំដំរីខេត្តតាកែវ!!ក៖ ហ្ហ៎!!!ខ៖ហើយដល់ពេលដាច់ជើងនៅទ័ពខេត្តណាស់!!ដល់ពេលដាច់ជើងមកដេកនៅពេទ្យ

កាលជំនាន់និងដីនៅពេទ្យស្វីស ពេទ្យស្វីសប្រហែលជាជំនាន់ 87 88អីហ្នឹង!!(1987 1988) ពេទ្យស្វីស ពេទ្យស្វីសនៅតាកែវតាកែវយើង!!

កៈ ចារបានជួយគាត់ឲ្យរួចពីសេចក្តីស្លាប់អញ្ចឹងទៅ!!!

ខៈ គេមើលតាមជំនាន់ហ្នឹងគេយកចិត្តទុកដាក់ណាស់កងទ័ព!!

កៈ ចាំខ្លាំងណាស់គាត់លោកពូ!!!

ខៈ ឥឡូវក៏គេយកចិត្តទុកដាក់ដែរ។

កៈ នឹងហើយដោយសារជាតិលោកពូណោះ ពូបងប្អូនទាំង 5នាក់និង 2 រៀបរាប់ឈ្មោះតាំងពីបងគេរហូតដល់ទៅពៅគេបានដែរឬទេ ថាតើគាត់ឈ្មោះអ្វីខ្លះដែរ?

ខៈ ខ្ញុំនិងហើយជាបងទេ។

កៈ លោកពូជាបងគេឈ្មោះ!!

ខៈ ហើយបន្ទាប់ខ្ញុំឈ្មោះកែវពូក។

កៈ កែវពូក?

ខៈ ហ្នឹងហើយអាកំបុតជើង។

កៈ ចាំហេតុបន្ទាប់មកទៀតលោកពូ?

ខៈ បន្ទាប់មកទៀតស្រីឈ្មោះកែវសារឿន។

កៈ ដល់ពេលពៅទេ?

ខៈ ពៅគេឈ្មោះមួយទៀតកែវរី។

កៈចាំ!!

ខៈមួយទៀតឈ្មោះកែវរ៉េត។

កៈ អញ្ចឹងឈ្មោះទាំង 5 ហើយលោកពូ?

ខៈ បាទនិងហើយទាំង 5។

កៈពូតាំងពីដើមឡើយនៅផ្ទះទាំងអស់គ្នានៅឯស្រុកយ៉ាងម៉េចដែលលោកពូដែលលេងសើចជាមួយបងប្អូន អនុស្សាវរីយ៍អ្វីខ្លះដែលលោកពូចាំអំពីពួកគាត់?

ខៈ ដល់ពេលពួកយើងជួបជុំគ្នាអញ្ចឹងមានអីស្រលាញ់គ្នាណាស់។

កៈចាំ!!!

ខៈស្រួលបួល ណាស់ពេលខ្ញុំទៅម្តងៗ ហាក់ឱបហាក់នេះពេលខ្ញុំទៅលេងស្រុកម្តងៗ ខ្ញុំមកនៅទីនេះប្រាំឆ្នាំហើយនៅមើលថៅមើលថៅអាយុ 5ឆ្នាំឲ្យចូលរៀនឥឡូវ!!

កៈលោកពូមូលហេតុអ្វីបានជាចំណាកស្រុកមកពីតាកែវមកនៅទីក្រុងភ្នំពេញវិញដោយសារមកពីតែមើលថៅនិងឬក៏មានមូលហេតុអ្វីផ្សេងទៀត?

ខៈអត់ទេមុននឹងមុនដោយសារថៅពីរនាក់យាយរបស់ខ្ញុំនិងថាមុនដំបូងគ្រាន់តែឲ្យមកមើលថៅនិងប៉ុន្តែខ្ញុំខ្ញុំមកមើលថៅថៅខ្ញុំមកដល់ទីនេះមុនដំបូងខ្ញុំធ្វើសំណង់ ធ្វើសំណង់មួយថ្ងៃបាន 2 ម៉ឺន 20000លុយខ្មែរនិងខ្ញុំធ្វើចង់ថ្ងៃណាឈប់ឈប់ទៅថ្ងៃណាធ្វើធ្វើទៅៗចឹងណាស់!!មិនសូវជាខំ!

កៈ ចាថ្ងៃណាធ្វើធ្វើទៅអញ្ចឹងទៅលោកពូ។

ខៈ ថ្ងៃណាធ្វើបានថ្ងៃណាមិនធ្វើមិនបាន ។

កៈ ចាំលើលោកពូក៏នៅតែធ្វើសំណង់ដែរមែនទេ?

ខៈ ខ្ញុំអត់ទេខ្ញុំមកនៅធ្វើការនៅផ្ទះគាត់ពីរឆ្នាំហើយតែមិនបាននូវរាល់ថ្ងៃទេ!!

កៈ រាល់ថ្ងៃ??

ខៈ មិនបានរាល់ថ្ងៃទេជូនកាលគាត់មានពេលគាត់ទេហើយបានមួយខែមួយខែបាន 10 10 ថ្ងៃអញ្ចឹងទៅ!!!

កៈចាំ!!!

ខៈអូនការបានមួយអាទិត្យជាង!!!

កៈ មកធ្វើស្មៅនៅផ្ទះលោកពូរបស់ខ្ញុំមែនទេ?

ខះបាទធ្វើស្មៅ!!!		ធ្វើអីកាលពីពេលនឹងពេលមុនទីនេះស្មៅទាំងអស់ទៅតែឥឡូវគាត់កាត់ទើបតែចាប់ចាក់សាបពេលកាលពីមុនសុទ្ធតែស្មៅ!!!

កះ ហ្អូហ្នឹងហើយ!!

ខះ ខ្ញុំមកជម្រះមកកាត់!!

កះ
ហ្នឹងហើយខ្ញុំស្មានតែលោកពូជាអ្នកធ្វើសំណង់នៅទីនេះអញ្ចឹងអ្នកថៃផ្ទះដីឲ្យលោកពូមើលស្មៅមើលអីអញ្ចឹងទៅលោកណោះ?

ខះ					ហ្នឹងហើយហើយខ្ញុំមកមើលមកថៃដើមឈើដើមឈើនិងហើយអាណាទេគាត់ឲ្យចងអោយដំរឹម ហើយគ្រាន់តែឲ្យវាល្អមើល។

កះចា!!

ខះចង់អោយតែវាល្អតែមើលអញ្ចឹង!!

កះ ហ្នឹងហើយពូខ្ញុំគាត់ចិត្តល្អខ្លាំងណាស់!!

ខះ កាត់ស្មៅចោលកន្រ្តៃគាត់មាន!!

កះ ខ្ញុំស្រលាញ់ពូខ្ញុំខ្លាំងណាស់!!!

ខះ									ពេល
គាត់ម្តងម្តងឃើញខ្ញុំធ្វើពេលថ្ងៃអញ្ចឹងគាត់មិនឲ្យធ្វើទេគាត់មកបោចស្មៅកន្លែងណាបន្តិចឲ្យដល់ទៅកន្លែងណាពេកក៏គាត់មិនឱ្យបោចន្លែងណាស្អិតពេកគាត់ក៏មិនឱ្យបោចដែរ!!!

កះ ចាំ!!

ខះ ខ្ញុំធ្វើតែពេលត្រជាក់ត្រជាក់។

កះ ចាំខ្ញុំស្រលាញ់លោកពូរបស់ខ្ញុំណាស់។

ខះ បើខ្ញុំនិយាយអំពីប្រវត្តិកូនប្រពន្ធវាពិបាកណាស់!!

កះ ឥឡូវលោកពូឈប់ពីប្រវត្តិប៉ុលពតសិននិយាយអំពីប្រវត្តិរបស់

លោកពូនិងបងប្អូនសិនមើលមាននៅចាំអ្វីទៀតទេពីបងប្អូនពួកគាត់ប្រវត្តិឥឡូវប្រវត្តិកម្សត់ជាងគេជាមួយបងប្អូនស្អីគេវិញ?

ខ៖ ប្រវត្តិកំសត់ជាងគេ?

ក៖ ចាំ!!

ខ៖ ប្រវត្តិកំសត់ជាងគេតែពេលជំនាន់ប៉ុលពតគេឲ្យទៅនៅ ខ្ញុំអាយុជំនាន់ប៉ុលពតអាយុ 12 ឆ្នាំដល់ 15ឆ្នាំគេអោយចូលកងចល័តហើយ បាទនៅតែកងចល័តទេ!!

ក៖ អញ្ចឹងរបាននៅក្មេងអត់សូវដឹងប្រហែលជាមិនសូវពិបាកមែនទេលោកពូ

ខ៖ អេក្មេងជំនាន់ប៉ុលពត!!យ៉ាប់ណាស់មីអូន!!

ក៖ ចាំបើនៅកុមារអាយុត្រឹមតែ 4 ឬ 5 ឆ្នាំអត់អី!!

ខ៖ 7 ឆ្នាំរស់ក 8 ឆ្នាំមិនដែលបាននៅជាមួយម្តាយទេមាននៅជាក្រុមរបស់ពួកគេ គេមើលអញ្ចឹងគេឲ្យសែងអាចម៍គោសែងចាក់ស្រែចាក់អីបាទ!!ហើយពិបាកណាស់នៃយើងរួមបបរក្មេងព្រលឹមឡើងរកតែបបសហូបមិនបាន!!

ក៖ ចាស់ឥឡូវលោកពូបង្វែរមកបងប្អូនសិនឥឡូវរាល់ថ្ងៃនៅតែរាប់អានគ្នាទៅវិញទៅមកជាមួយបងប្អូនទាំងអស់ហេ?

ខ៖ អត់អីទេពួកគាត់នៅតែរាប់អាន!!

ក៖ ពួកគាត់នៅខេត្តតាកែវទាំងអស់មែនទេលោកពូ?

ខ៖ នៅខេត្តតាកែវទាំងអស់បងប្អូនរបស់ខ្ញុំ នៅមូលគ្នាទាំងអស់។

ក៖ ចាំ!!មានប្តីមានប្រពន្ធទាំងអស់ហើយមែនទេ?

ខ៖ មានអស់ហើយទាំងប្រាំមានអស់ហើយ។

ក៖ ចាំអញ្ចឹងសុទ្ធតែល្អ!!

ខ៖ ខ្លះគេមានកូន2 កូនបី កូនមួយហើយ។

កៈ
លោកពូពេលនៅពីក្មេងល្បែងប្រជាប្រិយអ្វីដែលលោកពូចូលចិត្តលេងជាមួយពួកគាត់ជាងគេ?ដូចពេលនៅពីក្មេងទម្លាប់របស់លោកពូលេងជាមួយនឹងពួកគាត់រាល់ថ្ងៃយ៉ាងម៉េចដែរ?

ខៈ ពីតូចមកមែនទេ?

កៈ ចាំ!!!

ខៈ ពីតូចមកពីដើមមកគេចូលចិត្តលេងតែហឹង!!

កៈ ហឹងមែនទេ?

ខៈ ស្គាល់ហឹងដែរឬទេ?

កៈ អាហឹងជីកននឹងដីផ្ដឹសទៅនឹងមែនទេ?

ខៈ បាទបាទនឹងហើយ។

កៈ កាលពីខ្ញុំនៅពីក្មេងខ្ញុំលេងអា 1 ហ្នឹងដែរ!!

ខៈ ម៉េងពីដើមលេងតែហៅទេយើងប្រវែងប្រវែងនិងលេងហើយ!!

កៈ ចុះលោកពូមានតែលេងកំភ្លុកនោះទេអាដាក់ស្នឹគេយកឫស្សីមកដំៗហើយវាបាញ់ឈឺនោះ?

ខៈ កំភ្លុក!!

កៈ កំភ្លុកអញ្ចឹងមែន!!!

ខៈ កំភ្លុកអាហ្នឹងទៅលេងដែរ ល្បែងទាំងអស់ហ្នឹងសុទ្ធតែល្បែងបូរាណ ខ្ញុំដែលលេង!!

កៈ អាហ្នឹងតែបាញ់ត្រូវសុទ្ធតែខ្លោចសាច់មែនទេលោកពូ?

ខៈ បាទ!!បើសិនជាត្រូវឈឺដែរអាគ្រាប់កំភ្លុស!!ក្របៅអីហ្នឹងឈឺណាស់ បាញ់ត្រូវជើង!!

កៈ ប៉ុន្តែក្មេងឥឡូវគ្មានទៅអ្នកណាលេងទេមែនទេលោកពូណោះ?

ខៈ គេគ្មានលេងទេ ឥឡូវគេលេងសុទ្ធតែទំនើបកាំភ្លើងអីនោះ មានសុទ្ធតែ រកក្រោះរបស់គេទំនើបៗខ្លាំងណាស់ គេប្រើសុទ្ធតែតេឡេបញ្ជាងណោះ!!!

កៈ ចាវាដូចថាពីមួយជំនាន់ទៅមួយជំនាន់ វាវិវត្តន៍មែនទេពូណោះ!!!

ខ៖ បាទ!

ក៖ ចាំចឹងលោកពូសម្រាប់ចូលដល់ឪពុកម្ដាយរបស់លោកពូម្ដង!! ហ្នំអម្បាញ់មិញបងប្អូនលោកពូកើតនៅតាកែវទាំងអស់គ្នាមែនទេលោកពូ?

ខ៖ បាទ!! កើតនៅតាកែវប៉ុន្តែពួកវាតូចនៅជំនាន់ប៉ុលពតវានៅតូចតូច។

ក៖ ចា!! ឥឡូវចូលដល់ម្ដាយរបស់លោកពូម្ដង តើម្ដាយរបស់លោកពូឈ្មោះអ្វីដែរ?

ខ៖ ម្ដាយរបស់ខ្ញុំឈ្មោះព្រំ នុយ!!ឪពុកខ្ញុំស្លាប់ហើយ!

ក៖ ចាំ!! ម្ដាយរបស់លោកពូអម្បាញ់មិញឈ្មោះអ្វី?

ខ៖ ម៉ុម នុយ!!

ក៖ ម៉ុម នុយ?

ខ៖បាទ!!

ក៖គាត់នៅមានអាយុជីវិតរហូតដល់សព្វថ្ងៃលោកពូណោះ?

ខ៖ រស់នៅ ព្រះជន្មរបស់គាត់ប្រហែលជា 80ជាងហើយ!!

ក៖ 80ប៉ុន្មានហើយលោកពូ?

ខ៖ ប្រហែលជាបែប 83 84 ហើយ!!

ក៖ ចាំ!!ដឹងគាត់កើតឆ្នាំណាទេលោកពូ?

ខ៖ អត់ដឹងព្រោះតែខ្ញុំកើតមកពេលជំនាន់ហ្នឹងអត់បានរៀនដល់ពេល 79ខ្ញុំការចេញពីជំនាន់ប៉ុលពតមកខ្ញុំការ!!

ក៖ ចាំ!! ដូចឪពុកម្ដាយរបស់ខ្ញុំដែរ។

ខ៖ កាលពីការគ្មានមេក្រូគ្មានអ្វីទេ ភ្លេងរបស់គេមានតែស្គរមួយធុង1!!!វៃលេងចេះដាច់ខាតទៅនិយាយឲ្យត្រង់ពីការការប្រពន្ធមិនដឹងចេះស្រលាញ់ចេះអ្វីទេអត់ចេះទេអត់ចេះស្រឡាញ់អត់ចេះអ្វីទេ!!ពេលកាកាអាយុ 20 ឆ្នាំគត់ឆ្នាំ 79ដាច់!!!

កៈ
ចាំចឹងលោកពូសម្រាប់ម្ដាយរបស់ពូមកដល់សម័យឥឡូវអញ្ចឹងម្ដាយរបស់លោកពូឆ្នាំខ្មែរម្ដាយរបស់លោកពូកើតឆ្នាំអីគេដែរ សត្វអីគេ?

ខៈ ទេវតាយខ្ញុំដូចជាឆ្នាំគោ គោ!!

កៈ ឆ្នាំឆ្លូវមានទេលោកពូ?

ខៈ ឆ្នាំឆ្លូវបាទឆ្នាំឆ្លូវបើសិនជាឪពុករបស់ខ្ញុំគឺឆ្នាំរោង!!

កៈ ចាំ
លោកពូសម្រាប់ម្ដាយរបស់លោកពូគាត់កើតស្រុកកំណើតរបស់គាត់នៅភូមិឃុំណាដែរ?

ខៈ គាត់នៅទីហ្នឹងភូមិកំណើតហេតុខ្ញុំបានថាហ្នឹង!!!

កៈ ភូមិកំណើតជាមួយលោកពូដែរ នៅខេត្តតាកែវនិង?

ខៈ បាទនិងទីនិងជាមួយគ្នា នៅដីរបស់គាត់ទេបើគាត់ចែកអោយ!!

កៈ ចាំចឹង 5នាក់មានចំណែកទាំងអស់?

ខៈ នឹងហើយមានចំណែកចែកដីភូមិដី!!!

កៈ ដូចជាខ្ញុំដែរម៉ែរបស់ខ្ញុំចែកដីឲ្យ
5នាក់ខ្ញុំដែរ។លោកពូសម្រាប់អនុស្សាវរីយ៍កាដូជាការចងចាំអ្វីខ្លះដែលលោកពូចាំជាងគេជាមួយម្ដាយចាំជាងគេ?

ខៈ
ម្ដាយរបស់ខ្ញុំនិយាយទៅពេលខ្ញុំទៅម្ដងៗខ្ញុំរលឹកគាត់គាត់គ្មានដែនមាត់ទៅកូនណាមួយម៉ាត់ទេឪពុករបស់ខ្ញុំម្ដាយរបស់ខ្ញុំ!!

កៈ គាត់ល្អតែម្ដងមែនទេលោកពូណោះ!!

ខៈ ល្អណាស់!!

កៈ លោកពូ!!

ខះដូចជាខ្ញុំរាល់ថ្ងៃកូនទាំងប្រាំអ្នកដែរប៉ុន្តែខ្ញុំមិនដែលចេះសម្តីរករឿងកូនអ្នកកូនណាទេកូនរបស់ខ្ញុំដើរដោយគន្លងធម៌ទាំងអស់ អត់ចេះមាត់!!

កះ ល្អណាស់អញ្ចឹងលោកពូ!!!

ខះ ស្រលាញ់គ្នាមិនដែល ចេះឈ្លោះទេ!!! ពូកវា 3 នាក់នៅធ្វើការនៅភ្នំពេញអាក្មួយនោះមកម្តងម្តងប្រលែងដូចនេះអញ្ចឹងក្មួយប្រុសអាយុ 5 ឆ្នាំ!!!

កះ
ចាំលោកពូចំណុចកន្លែងណារបស់ម្តាយរបស់លោកពូដែលលោកពូស្រលាញ់គាត់ជាងគេ?ដែលថាដក់ជាប់នៅក្នុងអារម្មណ៍ដែលមិនអាចបំភ្លេចគាត់បានពីក្នុងចិត្តរបស់លោកពូៗចឹងណាស់?

ខះ
ស្រលាញ់គាត់កាលពីពេលដែលខ្ញុំនៅកងចល័តចុះគាត់នៅក្នុងភូមិនៅសហករណ៍ណាស់ប៉ុលពតណាស់គាត់មានអ្វីគាត់បានទៅយកអោយទោះ ម៉ោង 3 ម៉ោង 4ណាស់យកឱ្យកូនហូបហើយ
ហើយនៅកងចល័តនិយាយរួមនិយាយចង់ស្រក់ទឹកភ្នែកមីអូន។

កះ ហ្នឹងហើយ!!

ខះ ដាក់អង្ករ2កំប៉ុង 12 នាក់ដាក់ផ្លែព្រលិតតែព្រលឹតស្គាល់អាព្រលិតបឹងនិងទេ?ដែលស្គាល់ទេ
ព្រលិតបឹងវាមិនខ្វះទេជំនាន់និង!!

កះ ដែលស្គាល់តែផ្កា។

ខះ ព្រលិតយើងនឹងអាព្រលិត!!

កះ តែមើមរបស់វាមែនទេលោកពូ?

ខះ បាទ!!ផ្លែរបស់វាប៉ុនប៉ុណ្ណឹងហើយក្រពះបើពេលវាអីវាក្រហម!!

កះ វាលោតឡើងឬក៏វានៅក្នុងទឹក?

ខះ អត់ទេពេលនៅឡើយលើទឹកវាផ្លែខៃវស្សាអញ្ចឹងវាផ្លែហើយ!!

កៈ ខ្ញុំអត់ស្គាល់ផ្លែព្រលឹតនិងសោះស្គាល់ផ្លែព្រលិត។

ខៈ អាព្រលឹតហូបរាល់ថ្ងៃអាព្រលឹតរំចង់ទេតើ ព្រលិតគេលក់រាល់ថ្ងៃអាទិត្យក្រហមព្រលឹតរំចង់ ព្រលិតរបស់យើងអាព្រលិតខ្មៅខ្មៅ ហើយបាដើមរបស់វាគឺផ្អែមខ្លាំងណាស់ ផ្លែវាដកយកមកហូបក៏មានឥឡូវបើមានឥឡូវបើមានៈណាស់!!

កៈ ចាពេលជំនាន់ប៉ុលពតនិងបានសិនជាគ្មានអ្វីហូបមិនព្រមដកយកអាហ្នឹងនឹងយកមកហូបទៅលោកពូ?រឺក៏គេមិនអោយហូប?

ខៈ នៅស្រុកនិងគិតធ្វើស្រូវបានណាស់ធ្វើយ៉ាងម៉េចបើលេងវាដាក់សហករណ៍ដាក់នៅក្នុងនេះ។

កៈ គេមិនឲ្យទៅដក់ឥវ៉ាន់ទេមែនទេ?

ខៈ អោយតែឃើញមកដល់នេះឡានគេឡានគេដឹកចេញទៅគេដឹកចេញទៅណាគេដឹកចេញពីជង្រុកអញ្ចឹងទៅ!!!គេធ្វើបានខ្លាំងណាស់!!

កៈ អាហ្នឹងស្រូវមែនទេលោកពូ?

ខៈ គេធ្វើបានណាស់និយាយឲ្យត្រង់ទៅបានណាស់ពីរខែបីខែនឹងគេអោយបាយរឹងយើងហូប!!

កៈ អោយបាយដែរ!!

ខៈ តែ 2ខែទៅ 3ខែនិងចាប់បបរវិញហើយចែកគ្នា!!

កៈ ការនិយាយអម្បាញ់មិញនេះបកមកសំណួរក្រោយអំបាញ់មិញនេះលោកពូថាហេតុអ្វីពេលនឹងពូប្រាប់ខ្ញុំថាសំបូរព្រលិតផ្លែព្រលិតអីវ៉ាន់តែពេលនឹងមិនព្រមយកអាមួយនឹងហូបទៅ?

ខៈ កុំតែបាន តែកាលពេលហ្នឹងសុទ្ធតែបឹងទាំងអស់!!

កៈ តែពេលហ្នឹងបានបេះហូបដែរលោកពូណោះ??

ខ៖ បាទចុះខ្ញុំនៅតែកងចល័តនិងហូបនៅបឹងនិងត្រីក៏សំបូរដែរ!!

ក៖ តែហូបបានដែរឬទេ?

ខ៖
ហូបបើយើងបេះហូបជួនកាលខ្លះទៅគេត្រីឥវ៉ាន់យើងយើងយកមកអាំងហូបគេអត់អោយហូបទេ!!ប៉ុលពត!!និយាយទៅបើយើងត្រូវប្រធានកងប្រធានពលយ៉ាប់តែអាគ្នាឯងអញ្ចឹងអាខ្លះគេបានធ្វើមេក្រុមមេអីអញ្ចឹងទៅ
គេមិនអោយយើងហូបទេយើងយកមកស្លយកមកនេះអញ្ចឹងបន្លែត្រកួនព្រលិតខ្វះអីនៅស្រុកនិង!!

ក៖ ចាំ វាបានអាហ្នឹងសំបូរដែរប៉ុន្តែបើសិនជាហូប!!

ខ៖ បាទផ្កាពេលជំនាន់ហ្នឹងសំបូរណាស់គេគេអត់សូវមានអ្នករកណាស់!!មនុស្សវាតិច!!

ក៖
ចាំហ្នឹងហើយ!!ប៉ុន្តែដោយសារយកមុខយកមាត់អញ្ចឹងលោកពូណោះរបៀបហាត់អោយហូបតែហូបរាយការណ៍!!

ខ៖ នឹងដូចតែឥឡូវហ្នឹង
ប្រធានក្រុមរោងចក្រមានអីប៉ុន្តែតើអាពួកយើងគ្នាឯងហ្នឹងាំចេះតែស្អប់គ្នអញ្ចេះអញ្ចុះអញ្ចឹងទៅណាស់ !!

ក៖ បងប្អូនឯងសោះជនជាតិតែមួយសោះលោកពូណោះ??

ខ៖
ជួនកាលបងប្អូនខ្លួនឯងអីនឹងបងប្អូនខ្លួនឯងរាយការណ៍ទៅវាយកទៅវ៉ៃចោលទៅវាច្រើនតែអញ្ចឹងតើ!!

ក៖
ខ្ញុំឆ្ងល់ណាស់ពួកនិងពេលបែកពុំលពតមកពួកវាមានស្តាយក្រោយអីទេលោកពូដូចរបៀបថាបងប្អូនខ្លួនឯងវ៉ៃ ឪពុកម្តាយខ្លួនឯងសម្លាប់ចោលនោះ!!!

ខៈ ប៉ុលពតសំលាប់មូសសំលាប់គ្រាន់តែ អំរបស់ខ្ញុំនោះទេ2 ពូនោះមួយ!!!ប៉ុលពតមិនមែនប៉ុលពតយកទេតែគ្នាឯងហ្នឹងរាយការណ៍ទៅឆ្លបគេមកយកហើយយកទៅរៀនសូត្រទៅ។

កៈ អម្បាញ់បាញ់និងលោកពូម្តាយរបស់លោកពូលោកពូចាំជាងគេខំយកម្ហូបយកអាហារអោយលោកពូពិសានៅក្នុងជំនាន់ប៉ុលពតងើបតាំងពីម៉ោង!!

ខៈ ពេទ្យខ្ញុំអត់ពេលខ្ញុំឃ្លានកដៃរបស់ខ្ញុំប៉ុនប៉ុននេះទេកុំស្គមណាស់ដើរសឹងតែមិននិងអាក្បាលនេះធំជាង អាក្បាលនោះទៅទៀតក្បាលមួយៗ!!!

កៈ ពូកាលពេលហ្នឹងមិនដឹងមុននោះទៅជាយ៉ាងណាទេលោកពូអើយដល់ពេលស្គមពេកទៅ!!

ខៈ ឃើញស្អីក៏ ឃ្លានដៃរក្ខយអើយ អ្នកកើតជំនាន់ជំនាននិងវេទនាណាស់នៅស្រុកនិងមិនសូវបាននៅទេខ្ញុំឆ្នាំ77យួនគេវាចូលមកនោះរត់មួយសារទោល់តែឆ្នាំ78(1978) ជិតចូល៧79(1979)រត់មួយសារទៀត រត់មកនៅភ្នំនិងនៅដៃលែងកំពង់ស្ពឺ។

កៈ ភ្នំអ្វីលោកពូ?

ខៈ បាទ?

កៈ ភ្នំអ្វីម្យ៉ាងវិញលោកពូ?

ខៈ នៅស្លាបដែកភ្នំស្រង់ភ្នំអ្វីយើងនឹង!!

កៈ ស្លាប?

ខៈ ស្លាបលែងកំពង់ស្ពឺយើងនឹង!!

កៈ ស្លាបលែង??

ខៈ បាទ!!

កៈ ស្លាបលែងកំពង់ស្ពឺ!! រត់មកនៅទីនោះដែរ!!!

ខៈ នឹងរលឹកនៅទីណាតាមជួរភ្នំទាំងអស់នឹងទៅ!!!ដល់ពេលណាទព័គេវ៉ៃយួនដេញទៅវិញទៅបានគេអោយទៅនៅនិងវិញ

កៈ ពេលនិងអំឡុងឆ្នាំប៉ុន្មានលោកពូ?

ខៈ ពេលនឹង77 78(1977 1978)

កៈ អញ្ចឹងអំឡុងពេលប៉ុលពតយួនចូលមករហូតដែរមែនទេលោកពូហោ?

ខៈ ពេលចាប់យួននិង 78(1978)ហ្នឹង 77(1977)ចុង 77(1977) រហូតដល់ឆ្នាំ 79(1979)ពេលយួនវ៉ៃ!!

កៈ ហ្អូអញ្ចឹងយូដែរពេលហ្នឹង ទំរាំរំដោះចេញហ?

ខៈ បាទ3ឆ្នាំ!!ៗចេញកាលពីយើងរំដោះ 75 ហើយ(1975)។

កៈ ចូលរបបប៉ុលពត។

ខៈ បាតប៉ុលពតនិងពីឆ្នាំចិតប្រាំរហូតដល់ 78(1975 1978)!!

កៈ 79(1979) បែកមែនទេលោកពូ?

ខៈ បាទបាទ !!!ឆ្នាំ 75 យើងបែក(1975)នាងបែកភ្នំពេញហ្នឹង!!

កៈ ចាំ!!

ខៈ បាទបាទ!!!

កៈ អើយ!!លោកពូសម្រាប់ម្ដាយរបស់លោក ពូគាត់រកស៊ីអ្វីខ្លះដើម្បីចិញ្ចឹមគ្រួសារលោកពូ?

ខៈ ម្ដាយរបស់ខ្ញុំនិយាយឲ្យត្រង់ទៅតាំងពីដើមរហូតមកដល់ឥលូវគាត់ធ្វើតែស្រែ ក្មួយក្មួយខ្ញុំនៅផ្ទះក៏អញ្ចឹងដែរធ្វើការស្រែ មានរកស៊ីអ្វីទេធ្វើតែស្រែ ធ្វើតែស្រែបើខែនេះគេរកត្រីរកអីអញ្ចឹងទៅខែវស្សាសំបូរណាស់ស្រុកខ្ញុំឥឡូវក៏នៅតែសំបូរដែរ សុទ្ធតែបឹងហើយនិងទន្លេ!!

កៈ ឥឡូវនៅសុទ្ធតែសំបូរដែរមែនទេលោកពូ?

ខៈ បាទ នៅសំបូរ!!

កៈ នៅទីហ្នឹងគេហៅ ទន្លេអ្វីដែលលោកពូ?

ខ៖ ទេឈ្មោះវាគេតែទន្លេកំពង់អំពិល ទន្លេ ដៃទន្លេតូចដែរហ្នឹង!!បើខែវស្សាចូលដល់ខែទី 10 ខែទីដប់មួយទឹកអីហ្នឹងដូចជាសមុទ្រអញ្ចឹង
នៅតែកោះគេហៅកោះអណ្ដែតកោះអណ្ដែត!!ជុំវិញសុទ្ធតែទឹកទាំងអស់!!

ក៖ ចាំ អញ្ចឹងកន្លែងលោកពូនៅជុំវិញសុទ្ធតែទឹកទាំងអស់?

ខ៖ បាទ ប៉ុន្តែដល់ពេលខែប្រាំងអត់ទេប៉ុន្តែខែវស្សាទឹកជុំវិញទាំងអស់ទឹកវាឡើងមក។

ក៖ អញ្ចឹងឡើងមកលិចដីលិចផ្ទះអស់ហើយមែនទេលោកពូ?

ខ៖ លិច ដីប៉ុន្តែផ្ទះអត់លិចទេ!!

ក៖ ផ្ទះមកធ្វើនៅលើទួល?

ខ៖ បណ្ដែតភូមិខ្លះលិចដែរភូមិខ្លះនៅមួយម៉ែត្រពីម៉ែតអញ្ចឹងទៅ !!

ក៖ លោកពូ ភាគច្រើនអ្នកភូមិនៅទីនោះគេរកស៊ីអ្វីវិញ?

ខ៖ អ្នកភូមិនិងពីកំណើតគេធ្វើតែស្រែនឹង!!

ក៖ ស្រែទាំងអស់ហើយដល់ពេលឥឡូវ!!

ខ៖
ធ្វើស្រែឥឡូវគេធ្វើចេះតែខាតច្រើនតែកូនចៅមករោងចក្រមករោងអ្វីអស់ហើយនៅតែចាស់ៗ ហើយនឹងក្មេងរៀន!!

ក៖
ហ្នឹងហើយពេលមុនពេលជំនាន់មុនមានតែធ្វើស្រែបានតែឥឡូវធ្វើមិនដែលបានតែម្ដងមែនទេ លោកពូ?

ខ៖ វាស្រូវចុះថោកពេកពិបាកដែរហើយគេចេះតែឡើងថ្លៃ។

ក៖ ហើយឥឡូវលោកពូចូលដល់ ឪពុកលោកពូវិញឈ្មោះអ្វីដែលអម្បាញ់មិញ?

ខ៖ កែវកង!

ក៖ កែវកង??

ខ៖ បាទ!!

កៈ ចាំតែរកង!! ពូហ្នឹងហើយលោកពូឥឡូវគាត់អនិច្ចកម្មហើយមែនទេលោកពូ?

ខៈ គាត់ស្លាប់បាត់ហើយគាត់ស្លាប់ទើបតែប៉ុន្មាន 3 ឆ្នាំ។

កៈ 3ឆ្នាំ??

ខៈ បាទ!!

កៈ កូនស្លាប់នៅអាយុប៉ុន្មានដែលលោកពូ?

ខៈ គាត់ឆ្នាំរោងឆ្នាំរោង។

កៈ ឆ្នាំរោងលោកពូ?

ខៈ បាទ!!

កៈ តើអាយុប៉ុន្មានពេលហ្នឹងលោកពូគាត់ស្លាប់?

ខៈ មិនបានចាំមិនដឹងគាត់អាយុប៉ុន្មានទាល់តែមើលក្រដាស!!

កៈ ឪពុកបងលោកយាយប៉ុន្មានឆ្នាំម្តាយរបស់ឪពុកប៉ុន្មានឆ្នាំ?

ខៈ រោងហើយនឹងឆ្លូវគិតមើល!!

កៈ រោងហើយនឹងឆ្លូវ?

ខៈ បាទ!!

កៈ ហេអញ្ចឹងត្រូវប្អូនវិញហើយមែនទេ ត្រូវប្អូន?

ខៈ អត់ទេបងបងខ្ទង់ 6ឆ្នាំ 7ឆ្នាំ ឆ្នាំឯណោះ!!

កៈ ហ្អូហេ!! អញ្ចឹងបើសិនកាត់អាយុ 90ឆ្នាំហើយ!!

ខៈ 90ឆ្នាំហើយ!!

កៈ 91 ឆ្នាំហើយបើសិនជាគាត់រស់នៅដល់សព្វថ្ងៃឆ្នាំ 2018គាត់អាយុ 91 ហើយ។គាត់មានស្រុកកំណើតនៅឯណាដែលលោកពូ?

ខៈ ស្រុកកំណើតនៅទីហ្នឹងដូចតែគ្នាបាទ!!

កៈ នៅតាកែវនឹងតែមួយ?

ខះ មិនដែរគ្រាន់តែវាខុសភូមិ។នៅភូមិតាមិញ។

កះ ភូមិមិញ?

ខះ បាទ!!!ស្រុកកំណើតរបស់គាត់ម្ដាយរបស់ខ្ញុំនៅដើមចាន់!!

កះ តាអញ្ចឹងភូមិខុសគ្នាស្រុកខេត្តតែមួយ?

ខះ តែមួយតែមួយ។

កះ ចាំលោកពូឪពុករបស់លោកពូគាត់គឺជាមនុស្សដូចម្ដេចដែរ?

ខះ អាជីវកម្មរបស់គាត់ធ្វើតែស្រែ។

កះចាំការងាររបស់គាត់ហ្នឹងមែនទេ?

ខះបាទ!!

កះប៉ុន្តែគឺគាត់ជាមនុស្សយ៉ាងម៉េចដែរចរិកលក្ខណៈដូចជាលោកពូបើសិនជាខ្ញុំនិយាយថាលោកពូសុភាពឥវ៉ាន់អញ្ចឹងប៉ុន្តែឪពុករបស់លោកពូគាត់កាចឬក៏កូនស្លូតឬក៏យ៉ាងម៉េចដែរ?

ខះ ការងាររបស់ គាត់គ្មានមានការអ្វីទេឪពុកម្ដាយរបស់ខ្ញុំលឺតែខ្ញុំនិយាយគាត់ស្លូត។

កះ ដល់ក៏ហើយមែនទេ??

ខះ ឪពុករបស់ខ្ញុំគាត់ស្លូតជាងខ្ញុំទៅទៀតវត្ថមានអីទេហើយកូនគ្មានដែរគាត់ចាស់ប្រើចេះអ្វីទេ!!

កះ ធ្វើតែខ្លួនគាត់?

ខះ
បាទធ្វើប៉ុន្តែពីដើមកាលគាត់នៅជំនាន់យើងជំនាន់សម្ដេចតាស្រូវបីឆ្នាំអីវ៉ាន់ហូបមិនអស់ទេធ្វើស្រែឪពុកខ្ញុំធ្វើស្រែពូកែណាស់ធ្វើជាមួយនឹងគោរណាស់ដល់ពេលជំនាន់ឥឡូវវិញ!!

កះ គ្រឿងចក្រ!! គ្រឿងម៉ាស៊ីននមែនទេលោកពូ??

ខះ គេធ្វើសុទ្ធតែបានគេថ្លឹងលក់ឯណោះថ្នាក់ដីមួយហិកតាគេធ្វើបានដល់ទៅ ៦តោន 7 តោន!!ធ្វើមិនចង់រួចខ្លួនពីអូនឯងគិតមើលឪពុករបស់ខ្ញុំមួយហិចតាអ្នកណាគេល្អបាន 7 តោន7តោនស្រូវ!!

កះ ច្រើនណាស់!!

ខះ មិនសូវធ្វើបានតិចទេ 1ហិចតា 100 ម៉ែត្របួនជ្រុង។

កះ
ប៉ុន្តែបើសិនជាប្រៀបធៀបពេលមុនវាច្រើនជាងមែនទេលោកពូ?សម័យមុនណាស់!!ប៉ុន្តែឥឡូវលោកពូនិយាយពីសម័យមុនឬក៏សម័យឥឡូវ?មិនដែលបាន 7តោនក្នុង 1ហិតតាៗចឹងណាស់!!

ខះ អត់ទេនិយាយសម័យគេឥឡូវគេប្រើ !!កាលពេលមុនយើងធ្វើស្រែអាយើងធម្មតាធ្វើសម្រាប់កិនដែលហូបនិង!!!

កះ ចាំសម្រាប់តែហូបទេអញ្ចឹង!!

កះ
ឥឡូវលែងសូវមានបងហើយត្រីនៅស្រុកខាងខ្ញុំដូចអូនឯងសួរថាមានដីគេលក់ថោកឬក៏អត់!! ដីថ្លៃដីគេធ្វើស្រែមួយឆ្នាំគេធ្វើបាន 3 ដងឯណោះ!! កះហ្ហ!!ខះកន្លែងខ្លះធ្វើបាន 2 កន្លែងខ្លះធ្វើបាន 3!!

កះ ចាវាអាស្រ័យទៅតាមទឹកអញ្ចឹងទេលោកពូណោះ??

ខះបាទកុំអីបានបីទាំងអស់ប៉ុន្តែព្រោះតែវាមកពីដល់តែខែវស្សាទឹកវាឡើងមកលិចទាំងឡាយណាដែលមានបឹងធ្វើបានតែពីរដងអញ្ចឹងទៅ!!
ទឹកគេមានប្រឡាយទូកយួនដូចកប៉ាល់អញ្ចឹងមកទិញស្រូវរាប់រយតោនយួនវាមកទិញ!!!

កះ ចំៗចឹងវាមកទិញពីយើង?

ខះ វាមិនមកទិញប៉ុន្តែវាវាមានម៉ូយខ្មែរយើងជាអ្នកទិញទិញលក់អោយវាវាដឹងតែលើកទីម៉ូយវាអញ្ចឹង!!

កះ
អ្នកទទួលណោះ!!!លោកពូភាគច្រើនគេនិយាយថាពីខ្មែរយើងអញ្ចឹងណាស់លក់ទៅឲ្យប្រទេសគេជិតខាងអញ្ចឹងប៉ុន្តែប៉ុន្តែដល់ពេលវានាំចូលទៅប្រទេសខាងក្រៅតមួយទៀតណាស់វាថាស្រូវនិងជាស្រូវដាំនៅក្នុងប្រទេសនឹងទេមិនមែនជាប្រទេសដែលនាំមកពីយើងទេរបៀបថាវាចេញ

ពីយើងតែវាថាយកឈ្មោះរបស់គេយកទៅលាបដើម្បីលក់ឲ្យប្រទេសខាងក្រៅដើម្បីបានលុយច្រើនជាងនឹងទៀតឯណោះ!!

ខ៖ អាហ្នឹងអញ្ចឹងហើយ!!ដូចក្រុមហ៊ុនក្រុមហ៊ុនយួនរាល់ថ្ងៃយកស្រូវពីប្រទេសខ្មែរលក់ឲ្យជប៉ុនទេតើ!!

ក៖ ចាំហ្នឹងហើយ!!

ខ៖ ជប៉ុនប៉ុន្តែយើងអត់មានក្រុមហ៊ុននឹងគេ។

ក៖ ហ្នឹងហើយខ្ញុំអត់ដឹងយ៉ាងម៉េចដែរ!!!បន្តាយអត់អីទេរឿងខាងគេឯណោះ!!

ខ៖ ហើយស្រូវថោកលេង 1តោន 70 ឯណោះបានតែ 70!!

ក៖ $70??

ខ៖ 70 ម៉ឺន!!!

ក៖ 70 ម៉ឺន!!

ខ៖ 70 ម៉ឺនវា 100 ដុល្លារជាង!!!

ក៖ 70 ម៉ឺន180!!

ខ៖ ទេអត់ដល់ទេ!!!

ក៖ 70 មើល $180 ជាងហើយលោកពូ!!!185 185 ដុល្លារ!!

ខ៖ បាទបាទ!!

ក៖ ហ្នឹងហើយគិតតាមដុល្លា 40 គត់ណាស់លោកពូ!!!ចាអញ្ចឹងសម្រាប់ឪពុកលោកពូពេលគាត់នៅពីក្មេងដូចលោកពូនៅពីក្មេងអញ្ចឹងតើគាត់បានផ្តល់ដូចជាទូមានអ្វីខ្លះអោយលោកពូដើរលើផ្លូវយ៉ាងម៉េចខ្លះដើម្បីក្លាយជាមនុស្សល្អក៏ដូចឱ្យជាយ៉ាងម៉េចដែរអញ្ចឹងណាស់??ទូន្មានលោកពូយ៉ាងម៉េចដែរដូចជាលោកពូមានកូនរបស់លោកពូឲ្យហើយគាត់ទូន្មានពូយ៉ាងម៉េចដែរអញ្ចឹងណាស់??

ខ៖ កូនខ្ញុំគ្មានទេខ្ញុំទូន្មានឲ្យវាធ្វើតែអំពើល្អ!!

កៈ ចាប៉ុន្តែឪពុករបស់លោកពូមានលោកពូយ៉ាងម៉េចដែរកាលពីជំនាន់មុន?

ខៈ ដូចតែខ្ញុំនិយាយអញ្ចឹងគាត់អប់រំឲ្យតែកូនល្អកុំអោយអារឿងអាក្រក់រឿងអីកុំអោយធ្វើ បើខ្ញុំមកធ្វើនៅពីនឹងសួរតែលោកទូទៅការនេះខ្ញុំសំគាត់ទេតើចង់ហូបអ្វីសម!!ប្រាប់គាត់អញ្ចឹងទៅជូនកាលមិនបាច់នេះគាត់បេះហើយអញ្ចឹងទៅ!!!ដល់ពេលអញ្ចឹងបេះអើយ!!

កៈ ក្រូចឆ្មារ រំដេញ!!គាត់បេះអើយ ស្វាយវិញ បើស្វាយបើខែមៀន!!!ដល់ខែសម្បូរណាស់!!

ខៈ ហ្នឹងហើយមៀនផ្លែច្រើន!!!

កៈនៅទីនោះផ្លែច្រើនណាស់ តែមៀននៅនៅចំលោកពូ!!

ខៈ ឥឡូវចាប់ក្តីបទៀតហើយ ហើយឥឡូវស្វាយផ្លែអត់សូវដឹងខែទេ!!បន្តិចផ្លែបន្តិចផ្លែ!!

កៈ
អញ្ចឹងលោកពូបន្តទៅទៀតសម្រាប់ជីដូនជីតាលោកតាលោកយាយខាងម្តាយរបស់លោកឈ្មោះអ្វីទេ។

ខៈ តាយាយខាងម្តាយ?កៈចា៎!!!ខៈក្រមុំយាយនាងហ្នឹង!!

កៈ ចាំត្រកូលរបស់គាត់ដែរឬទេ?

កៈ ត្រកូលបានចាំទេ!!!ស្គាល់តែឈ្មោះយាយមុំតានាង?

ខៈ បាទ!!

កៈ ចាតើគាត់ជាអ្នកស្រុកមកពីណាដែលលោកពូទាំងពីរនាក់នឹង?

ខៈ កាលពីដើមឡើយស្រុកកំណើតរបស់គាត់នៅតែទីហ្នឹងបណ្តោយ!!

កៈ បណ្តោយតែម្តងលោកពូហេ??

ខៈ ភូមិដើមចាន់កោះអណ្តែតឃុំរមេញ!!

កៈ
ចា៎លោកពូឥឡូវនិយាយអំពីលោកយាយតើលោកពូកើតទាន់លោកយាយដែរឬទេគាត់ឥឡូវគាត់នៅរស់ដែរឬទេ?

ខៈ លោកយាយពីដើមហ្នឹង?

កៈ ចាំ!!

ខៈ យាយមុំតានាងហ្នឹងហោ?

កៈ ចាំ!!!

ខៈ ខ្ញុំកើតទាន់តាមុំ ប៉ុន្តែយាយនាងខ្ញុំកើតអត់ទាន់ទេ។

កៈ ឥឡូវនិយាយពីតាមុំមើល?

ខៈ តាមុំកាលពីខ្ញុំកើតអាយុទើបតែចេះដើរទូចអាយុខ្ញុំបានហើយជា 5 ឆ្នាំនិងខ្ញុំនៅចាំគាត់។

កៈ យ៉ាងម៉េចដែរលោកពូនិយាយមើល?

ខៈ ខ្ញុំចាំយ៉ាងម៉េចបើខ្ញុំអាយុ 5 ឆ្នាំខ្ញុំមិនដឹងពីប្រវត្តិគាត់គាត់ធ្វើតែស្រែធ្វើតែចំការដាំតើដំណាំអញ្ជឹងដូងស្វាយខ្នុរអ្វីមិនចេះខ្ចាស់គេដីរបស់គាត់ធំណាស់ដែគាត់ចែកដោយប៉ុន្តែតាមុំកូនគាត់ មីងនី អំណៃ អំណែម ហើយបានម្តាយរបស់ខ្ញុំនិងហើយលោកពូរបស់ខ្ញុំកូនប្រុសតែមួយទេ ពូសៅ!! បានមីងណាន មីងងោល ។

កៈ ហើយចុះម្តាយមានដែបានប្រាប់អ្វីពីយាយមានហោ?

ខៈ បាទ!!

កៈ  យាយនាងឬក៏អត់ថាគាត់ជាមនុស្សយ៉ាងម៉េចដែរ យាយនាង?

ខៈនាងគាត់និយាយថាឮម្តាយរបស់ខ្ញុំប្រាប់ថាកត់សស្អាតណាស់ប្រហែលជាកូនកាត់ចិនកូនកាត់អីមិនដឹងទេសរស្អាតណាស់បើសិនជាតារបស់ខ្ញុំរាងខ្ពស់ប៉ុន្តែខ្មៅតាមុំរាងខ្ពស់!!

កៈ ហ្នឹងហើយ!! លោកពូ លោកពូកកើតទាន់ចេញទេដឹងថាលោកពូដឹងថាគាត់កើតឆ្នាំណាទេលោកពូម្តាយមានដែលប្រាប់ដែរឬទេ?

ខៈ អត់ទេអត់ដឹងទេមិនចាំទេ។

កៈ យូរហើយមែនទេលោកពូ?

ខ៖ បាទ!!

ក៖ ចុះចំណែកតា !! តាពេលនឹងលោកពូនៅអាយុ 5 ឆ្នាំគាត់អាយុប៉ុន្មានវិញ?

ខ៖ ខ្ញុំមិនដឹងទេជំនាន់ហ្នឹងគ្មានអ្នកណាគេនៅចិនយូហើយ!!

ក៖ តែកូនស្លាប់ជំនាន់ប៉ុលពតមានទេ?

ខ៖ អត់ទេ!! គាត់ស្លាប់តាំងពីជំនាន់សម្តេចតាឯណោះជំនាន់សម្តេចតា!!!

ក៖ ហ្នឹអញ្ចឹងគាត់អត់បានឆ្លងកាត់ជំនាន់សង្គ្រាមទេ!!

ខ៖ ជំនន់អស់ទាំងហ្នឹងខ្ញុំទើបតែអាយុ 5 ឆ្នាំហ្នឹង!!!

ក៖ ចញ្ចឹងឆ្នាំ 1965 គាត់ស្លាប់អញ្ចឹងណោះ!!!

ខ៖ បាទ៎!!!

ក៖ មុនតែអត់ដឹងថាគាត់អាយុប៉ុន្មានឆ្នាំផងហ្នឹង???

ខ៖ អាយុរបស់គាត់ប៉ុន្មានខ្ញុំមិនដឹងទេ!!

ក៖ តែរាងចំណាស់ដែរឬទេ ពេលនឹងលោកពូគាត់លោកពូរឿងចាំបន្តិចទេថាគាត់ចំណាស់ណាស់ពេលនឹង?

ខ៖ ហ្នឹខ្ញុំមិនចាំទេ!!

ក៖ ចាំ!!តែលោកពូមិនសូវចាំទេ!!អញ្ចឹងឥឡូវដល់ជីដូនជីតាខាងឪពុកវិញតើយើងឈ្មោះអីគេដែរលោកពូ?

ខ៖ តាខាងឪពុករបស់ខ្ញុំមែនទេ?

ក៖ ចាំ!!!

ខ៖ មាស់តាកែវយាយនាង!!

ក៖ តាកែវយាយ??

ខ៖ ហាយាយគង់!!

កៈ យាយគង់!!

ខៈ យាយគង់!!

កៈ ចាំនត្រកូលរបស់តា កែវយាយគង់ដែរឬទេ?

ខៈ អត់!!អត់ចាំទេ!

កៈ អត់ចាំដែរ!! កើតទាន់គាត់ទាំងពីរនាក់ដែរឬទេលោកពូ??

ខៈ អត់ទាន់ទេ!!

កៈ ដែលឪពុកគាត់ប្រាប់ថាយ៉ាងម៉េចដែរតាយាយ?

ខៈ
ប្រវត្តិនៅទីនោះពីដើមគាត់ធ្វើតែស្រែគាត់ធ្វើតែស្រែធ្វើចម្ការដាំដំណាំចាស់ពីដើមបីរបស់គាត់ដីធំៗវាទូលាយណាស់ពីដើម!!

កៈ ចាអត់សូវមានមនុស្សច្រើន!!

ខៈ ដល់តែបែក ម៉ែកូនច្រើនចែកៗចឹងទៅម្នាក់ម្នាក់កូនច្រើនណាស់ពីដើមពីដើម!!តិចបំផុតក៏ 10 នាក់ឡើងដែរកូនទាំងអស់ណាស់មិនដូចឥឡូវទេ!!

កៈ ឥឡូវគេដូចថាការអប់រំសុខភាពឥវ៉ាន់និងវាមានច្រើនអញ្ជើញទៅណោះ!!

ខៈ បាទបាទ!

កៈ នៅមន្ទីរពេទ្យនិងថ្នាំចាក់មានថ្នាំអ្វីច្រើនឡើយទេជំនាន់មុនអត់ទេតាមដំណើរពីធម្មជាតិអញ្ចឹងតែម្តង!!
លោកពូសម្រាប់ឪពុករបស់លោកពូស្រុកកំណើតរបស់គាត់នៅតាកែវនិងតែម្តងឬក៏នៅឯណាវិញ?

ខៈ គាត់នៅភូមិនៅទីនោះភូមិរមេញតាកែវនិងដូចតែគ្នា!!

កៈ ចាំ!! អញ្ចឹងកន្លងជាមួយគ្នាគឺថានៅជាមួយគ្នានៅភូមិឃុំជាមួយគ្នានិងតែម្តង?

ខៈ បាទនៅជាប់ៗគ្នាហ្នឹង!!គ្រាន់តែខុសភូមិ!!

កៈ ចាំ!! ហ៊ីល្អទេតើ!!

ខ៖ ចាប់ពីដើមកក់ច្រើនៗចឹង គាត់អត់សូវ!!!

ក៖ សម្រាប់បងប្អូនកូនចៅរបស់លោកពូឬក៏តាយាយពរមានដែលធ្លាប់ដឹងទេថាគាត់រស់នៅប្រទេសខាងក្រៅអីដែរទេឬក៏ទៅធ្វើការនៅខាងក្រៅអ្វីខ្លះដែរទេ?

ខ៖ អត់ទេ!!

ក៖ នៅតែស្រុកខ្មែរ?

ខ៖ បាទនៅតែស្រុកខ្មែរ ស្រុកកំណើតនៅឯស្រុកកំណើត បើសិនជាពស់នោះមួយគាត់គាត់មករៀនរៀនទៅហើយគាត់មកធ្វើការនៅភ្នំពេញ!?

ក៖ ចាំគាត់ទៅរៀននៅឯណាវិញ?

ខ៖ ពូ ពូសៅណាស់គាត់ទៅរៀននៅភ្នំពេញយើងកើតពេលរៀននិងរៀននៅម្ដុំស្អាតចាស់!!គាត់មកនៅពីនិងរូបថតមករៀននៅស្អាតចាស់ស្អាតចាស់!!

ក៖ ចាំលោកពូនិយាយថារស់នៅប្រទេសក្រៅតែម្ដងមិនមែនរស់នៅស្រុកផ្សេងនៅក្នុងប្រទេសខ្មែរនឹងទេប៉ុន្តែដូចជានៅថៃវៀតណាមអាមេរិចអីវ៉ាន់អញ្ចឹងណាស់ បារាំងអីវ៉ាន់ចង់ទៅណាស់អត់ដែរទៅឯណាមែនទេ?

ខ៖ អត់ទេ។

ក៖ នៅតែក្នុងនិងទាំងអស់?

ខ៖ អត់មានដែលបានទៅ!!

ក៖ ប៉ុន្តែលោកធ្លាប់បានចេញចូលប្រទេសវៀតណាមមែនទេ?

ខ៖ ទៅប្រទេសវៀតណាមខ្ញុំធ្លាប់!!

ក៖ ហ្នឹងហើយ!!

ខ៖ ខ្ញុំធ្លាប់!!!

កៈ នឹងហើយគ្រាន់តែចេញចូលប្រទេសវៀតណាមទិញដូរកស៊ីអញ្ចឹងទៅមែនទេលោកពូ?

ខៈ ទៅប្រទេសថៃអត់បានទៅទេបើទៅលេងបងជីដូនមួយនៅបន្ទាយមានជ័យ!!

កៈ ទៅប៉ុន្តែមិនទាន់ទៅចូលដល់ដីថៃទេ!!!

ខៈ អត់ដែលទៅទេថៃ។

កៈ ចាំ!!លោកពូសម្រាប់!!លោកពូមានអ្វីដែលចង់និយាយបន្តិចទៀតអម្បាញ់មិញ??

ខៈ បាទ??

កៈ មានអីចង់និយាយបន្តិចទៀតទេ!!

ខៈ បាទបានហើយប៉ុណ្ណឹង!!

កៈ អត់ទេនិយាយរបៀបថាអម្បាញ់មិញទៅប្រទេសក្រៅអីអញ្ចឹងណាស់??ប្រហែលជារំខានពេលវេលារបស់លោកបន្តិទៀតដោយសារវាពុំទាន់បានចប់នៅឡើយទេ!!

ខៈ បាទបាទ!!

កៈ លោកពូជ្រុលនិយាយម្តងទៅហើយនិយាយអោយអស់តែម្តងទៅលោកពូទុកអោយកូនចៅស្តាប់អញ្ចឹងទៅណា!!!

ខៈ អត់អីទេ!!

កៈ អញ្ចឹងលោកពូសម្រាប់ចូលដល់ការសិក្សាវិញ សម្រាប់ការសិក្សាលោកពូ រៀនបានដល់ថ្នាក់ទីប៉ុន្មានដែរ?

ខៈ ខ្ញុំអត់បានរៀនទេ!! លឺថាពេលចូលឆ្នាំ 79(1979)រំដោះ 79 និងមកការបណ្តោយ។

កៈហ្ហ៎!!

ខៈការបណ្តោយអត់បានរៀននិងណាស់។

កៈ អុញហើយចុះពេលជំនាន់លន់នល់និងនោះ លោកពូនៅអាយុក្មេងដែល!!

ខះ
ជំនាន់លន់នល់រវល់តែរត់ពួចថាលោកនៅតែខាងលើតើនៅទីនោះនៅក្បែរបងនៅក្បែរនេះបងគ្មានបានទូវគេរត់រត់ទៅរត់ រត់ពីកោះ អណ្តែតរត់ទៅរហូតទៅ។

កះ ចាំរវល់តែពួរត់ពេក!!

ខះ បាទ!!រវល់តែពីរត់ជំនាន់ប៉ុលពតងាកទៅរត់ងាកទៅរត់វាលនិងយើងរត់កាត់តាមព្រំដែននោះ!!

កះ ចាចុះពេលគេចូលរៀនអក្ខរកម្ម លោកពូមានដែលចូលរៀនដែរឬទេ?

ខះ ខ្ញុំរៀនឌីហ្សាញអក្សរអីខ្ញុំមើលរួចខ្លះខ្លះដែរ៕

កះ អញ្ចឹងដោយសារៀនអក្ខរកម្មបានជាលោកពូរៀនចេះមើលអក្សរបានដែរហើ?

ខះ បាទចេះមើលរួចខ្លះផងដែរ!!

កះ ហ៎្ន!!!

ខះ បន្តែបើសិនជារឿងសាលាអត់ដែលអត់ដែលបានរៀនទេ!!

កះ អញ្ចឹងសរសេរអីវ៉ាន់លោកពូសរសេរបាន?

ខះ សរសេរបានបន្តិចបន្តួច!!

កះ ចាំហ្នឹងហើយ!!

ខះ ធ្លាប់ដែលសរសេរ!!

កះ
អញ្ចឹងដោយសារសង្គ្រាមអញ្ចឹងធ្វើអោយការសិក្សារបស់លោកពូអត់បានអញ្ចឹងទៅលោកពូណោះ??

ខះ រត់ជាប់រហូតតាំងពីខ្ញុំកើតមក!!

កះ ភ័យរហូតតែម្តង!!

ខះ ចុះកាលពីជំនាន់70មកដល់ 75ជំនាន់ពលពតខ្ញុំអាយុ 13 ឆ្នាំរហូតដល់ 15 ឆ្នាំដល់ជំនាន់ទី 70 ខ្ញុំអាយុប្រហែលជា 7 ឆ្នាំហោ!!ប្រហែលជា 6 ឆ្នាំ!!

កៈ ជិតអាយុដល់ 10 ឆ្នាំហើយលោកពូ!!!

ខៈ 5 ឆ្នាំមកដល់ឆ្នាំ 70 5 ឆ្នាំទៀត។

កៈ ហ្នឹងហើយ!!!

ខៈ ដល់ពេលឆ្នាំ 70(1970)ខ្ញុំឡើងដល់អាយុ 12ឆ្នាំ 13 ឆ្នាំហើយអាយុ 13 ហើយ។

កៈ លោកពូៗចឹងដល់ពេលអត់ដែលរៀនអញ្ចឹងប៉ុន្តែមានដែលគិតថាក្រីស្រមៃពេលធំឡើងចង់ធ្វើការអីអត់?

ខៈ ហេ៎ នឹកឃើញខ្មាស់គេដែរប៉ុន្តែយើងមិនចេះអញ្ចឹងមីអូន!!

កៈ ចាប៉ុន្តែលោកពូមានដែលមានក្តីស្រមៃថាធំឡើងចង់ធ្វើអ្វីមួយដែរឬទេ?

ខៈ មិនដឹងចង់ធ្វើអីបើនឹកឃើញខ្លួនឯងធ្វើអ្វីមិនកើត ប៉ុន្តែកូនខ្ញុំខ្ញុំអោយរៀនគេចប់បាក់ឌុបបាត់ដែរហើយកូនកូនខ្ញុំ 4 5 សុទ្ធតែចប់បាក់ឌុបហើយ។

កៈ កុំឲ្យដូចជាលោកពូមុនដោយសារពួកគាត់គាត់មានឱកាសដើម្បីរៀនហើយឲ្យគាត់រៀនទៅ។

ខៈ បាទអោយរៀនរៀនទៅបានរៀនធ្វើការងារអីនឹងគេ!!

កៈ ចាតែឥឡូវមកធ្វើការនៅភ្នំពេញមកធ្វើការរោងចក្រ រោងអីអញ្ចឹងទៅលោកពូណោះ?

ខៈ មកនៅរោងចក្របីនាក់!!

កៈ ចា៎!!!

ខៈ វាមកមានប្រពន្ធ អាបងមានប្រពន្ធនៅកំពង់ចាម អាហ្នឹងវាប្រលងបាក់ឌុបជាប់បើអាប្អូនបាក់ឌុកបាក់អីវាអត់ជាប់ធ្លាក់អាហ្នឹងវានៅនឹងស្រុកកំណើត!!

ខៈ បើកូនស្រីទាំងពីរនេះប្រលងជាប់បាក់ឌុប។

កៈ
ចាំចឹងលោកពូបានពុកគាត់រៀនច្រើនដែលប្រលងជាប់បាក់ឌុបលោកពូឲ្យពួកគាត់វិញទាំងអស់!!

ខៈ បាទ!!

កៈ លោកពូសំរាប់ចូលដល់ក្រុមគ្រួសាររបស់លោកពូថាប្រពន្ធរបស់គាត់ឈ្មោះអីគេដែរ?

ខៈ ប្រពន្ធរបស់ខ្ញុំឈ្មោះគៀត យ៉ា!!

កៈ សំម្តងទៀតលោកពូ?

ខៈ គៀត យ៉ា។

កៈ គៀត យ៉ា??

ខៈ បាទ!!

កៈ ឥឡូវគាត់សព្វថ្ងៃអាយុប៉ុន្មានហើយលោកពូ?

ខៈ ប្រពន្ធខ្ញុំហើយនិងខ្ញុំដំណាលរគ្នាប្រហាក់ប្រហែលគ្នា។

កៈ ហ្នឹងអញ្ចឹងប្រពន្ធរបស់លោកពូកើតឆ្នាំ 1960?

ខៈ បាទបាទ!!

កៈ ហើយឆ្នាំអម្បាញ់មិញឆ្នាំដែលលោកពូឆ្នាំអីគេវិញលោកពូ?

ខៈ ឆ្នាំជូត។

កៈ ឆ្នាំជូតដូចគ្នាអញ្ចឹងដំណើរគ្នាអញ្ចឹងចាគាត់នៅស្រុកមកពីណាវិញលោកពូ?

ខៈ នៅភូមិជាមួយគ្នានឹង។

កៈ នៅភូមិជាមួយគ្នាទៀត??

ខៈ ខ្ញុំរត់ទៅគិតទៅខ្ញុំកាលជំនាន់នេះនិងខ្ញុំនៅកងចល័តខ្ញុំរត់ទៅបែកពីម្តាយ 2
ម៉ែត្រពីអីអញ្ចឹងទៅមុនប្រហែលជាដាច់ 79
បានជាខ្ញុំទៅដល់គាត់ផ្សំផ្គុំខ្ញុំឲ្យបណ្តោយទៅមិនបានប៉ុន្មានប្រហែលជាកន្លះខែអីនឹង!!!

កៈ យី!!

ខៈ មិនដែលស្គាល់មុខប្រពន្ធស្គាល់អ្វីផង!!

កៈ ភាគច្រើនដូចជាជំនាន់មុនលោកពូណោះ?

ខៈ បាទ!!!

កៈ ចាំលោកពូតើប្រពន្ធរបស់លោកពូពេលរៀបការនិងពេលជំនាន់បែកភ្លាមលោកពូមានឱ្យជាបណ្ណាការឬក៏អីអីអត់ឬក៏គ្រាន់តែអោយតែបានការការទៅ?

ខៈ ជំនាន់និងគេមានថ្លៃដែរតើមីអូន!!

កៈ ចាំ??

ខៈ ថ្លៃជំនាន់ហ្នឹងវាការចំណូលនិងយើងអត់មានលុយចាយមានតែមាសហើយនិងនេះ!!

កៈ អញ្ចឹងហើយមាសជាជំនូនតើមែនទេលោកពូ?

ខៈ បាបអោយមាសហើយអោយថ្លៃគេមាសមួយជីបាតតើខ្លះអត់អញ្ចឹងទេខ្លះម៉ែខ្ញុំគាត់មានគតិធ្លាក់អញ្ចឹងគាត់ឲ្យទៅ!!

កៈ ផ្កាក៏ធ្លាក់បានទៀតណាស់នៅជំនាន់និងជំនានប៉ុលពត??

ខៈ បាតគាត់បានដំក្រវិលអោយកូនប្រសារគាត់មិនឲ្យជំនូនទេការហើយក៏សុំក្រវិលឲ្យកូនពាក់អញ្ចឹងទៅ!

កៈ ហ្អ!!អញ្ចឹងជូនជាកាដូអញ្ចឹងដែរលោកពូណោះ??

ខៈ បាទ!!!

កៈ គួរសម្រាប់ពេលលោកពូអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកមីងហើយលោកពូមានកូនប្រុសស្រី 5 នាក់ដែរយ៉ាងមិញប្រាប់មែនទេ?

ខៈ បាទ!!

កៈ ចាំ!!ពូប្រាប់ឈ្មោះកូនរបស់លោកពូទាំង 5 នាក់និងមើលតាពៅគេដល់!!បងគេរហូតដល់ទៅពៅគេគាត់ឈ្មោះអ្វីខ្លះលោកពូប្រាប់មក?

ខៈ បងតើបងឈ្មោះគេឈ្មោះកង វ៉ា តារបស់គេឈ្មោះកង កងវ៉ា!!ហើយអាបន្ទាប់នោះឈ្មោះកង រ៉ុម អាបន្ទាប់ទៀត កងវាសនា ហើយមីស្រីបងនោះកងបូផា មួយកងបូភៀន មីពៅនោះ។

កៈ ចាំចឹងលោកពូ 3 ប្រុសពីរលើហើយស្រី 2 នាក់ទៀត?

ខៈ បាទ!!!

កៈ ហោងហើយបានកូនស្រីដែរលោកពូ ដូចជាម្ដាយខ្ញុំដែរម្ដាយរបស់ខ្ញុំមានកូន 6 នាក់ប៉ុន្តែស្លាប់អស់អញ្ចឹងមួយទៅណាស់លោកពូ3 ប្រុសហើយបានស្រីស្រីមកបីនាក់ទៀតថែមទៀតអញ្ចឹងទៅណាស់ប៉ុន្តែស្លាប់មួយ!!ដោយសារជំងឺគ្រុនឈាមពីរជំនាន់គេរកអត់ទាន់ឃើញនោះ!!

ខៈ បាទអត់សូវមានថ្នាំមិនអីទេ មិនទាន់មានពេទ្យមានអ្វីឯណា!!

កៈ ចាំហ្នឹងហើយ!!

ខៈ ដូចពេលនឹងប្អូនរបស់ខ្ញុំនៅស្រុកខ្ញុំពេលគេកំបុតជើងមានទៅពេទ្យពេទ្យមាននៅតាកែវឆ្ងាយនិងពេទ្យនៅតាកែវជំនាន់និងគ្មានឡានគ្មានអ្វីទេមិនមែនដូចជាឥឡូវទេថ្នាក់គ្នាត្រូវតាំងពីជំរឺមោលនឹងមកសែរមកសែរមកតាកែវពេទ្យទ័ពពេទ្យពេទ្យនឹងគេទៅហើយវាស្គាល់គ្នាអ្នកជំនាញការគេគេអោយ!!

កៈ លោកពូអើយមិនដឹងគាត់ទ្រាំប៉ុណ្ណាទេបន្តែសន្លប់បាត់ហើយមែនទេ?

ខៈ ហ៊ឹ មកដល់ ពេទ្យពេលគេយកមកដាក់កន្លែងសាលខ្មោចកុំតែបានបងរបស់ខ្ញុំមួយគាត់ធ្វើការនៅពេទ្យខេត្តនិងគាត់គាត់ដឹងក៏ដឹងគាត់ទៅមើលបានគេយកចិត្តទុកដាក់សេរ៉ូមដាក់អ្វីអោយកុំអីដាក់សារខ្មោចចោលស្លាប់ទៅបើយើងគ្មានបងប្អូនគេមិនសូវយកចិត្តទុកដាក់ កាលពេលនៅធ្វើការនៅទីនោះបន្ថែមផ្កាពេលនិងបងប្អូនជីដូនមួយគាត់ចាត់តាំងខេត្តជំនាន់និងតាគង់ វ៉ាន គាត់អត់ចេះអក្សរអីទេតាគង់ វ៉ាន តើពេលនឹងគាត់ចៅហ្វាយខេត្ត។

កៈ ឥឡូវហ្នឹងមែនទេ?

ខៈ អត់ទេតាំងពីជំនាន់ឆ្នាំ 79(1979) ។

កៈ ហ្ហ៎ បានហើយចេះតែដាក់ឡើង!!

ខៈ ឥឡូវឡើងប៉ុន្មានថៅហ្វាយខេត្តហើយមិនបានស្គាល់ទេ ដូចច្រើនពេក ខ្ញុំមកនឹងដូរអស់ប៉ុន្មានហើយថៅហ្វាយខេត្ត ខ្លះបានប្តូរថៅហ្វាយខេត្ត។

កៈ
ចាំចឹងមកពូគំពូលទាំងអស់បានប្រាប់ថាគាត់បានទៅរៀនបន្តអត់បានធ្វើការងារអីច្រើនប៉ុន្មានទេតែបានអោយគាត់ចេះអានចេះសរសេរអក្សរខ្មែរដែរអញ្ចឹងមែនទេលោកពូ?

ខៈ ចេះកូនស្រីទាំង 2 ខ្លះចេះអង់គ្លេសអីទៀតសោះ។

កៈហ្ហ៎!!

ខៈ វាល់ថ្ងៃវាធ្វើរោងចក្រប៉ុន្តែវាធ្វើសុទ្ធតែប្រធានគេដែរ!!វាមិនសូវយ៉ាប់គេទាំងពីរនាក់ហ្នឹង។

កៈ និយាយថាឥឡូវពួកគាត់ទាំងពីរនាក់ចិញ្ចឹមលោកពូវិញដែលអត់?

ទាំង 5 នាក់នឹង?

ខៈ វាចិញ្ចឹមខ្ញុំដែរទេតើមកធ្វើនៅទីនោះប៉ុន្តែចេះតែកុំអីវាមិនអោយមកធ្វើទេកូនទាំងពីរ មីមួយពៅមិនទាន់មានប្តីទេ។អាយុ 20 ឆ្នាំជាងហើយ 22។

កៈ
ចាហើយគ្រាន់តែលោកពូមកធ្វើការនិងគ្រាន់តែមានរបៀបថៃឲ្យយឺតសរសៃយឺតសរសូងឥវ៉ាន់អញ្ចឹងទៅលោកពូណោះ?

ខៈ ដូចមហាតប្រាណបាននៅស្មៀមវានេះ!!

កៈ វាឈឺមែនទេលោកពូ?

ខៈ បាទ៎!!!ទៅមកអញ្ចឹងទៅ ដូចហាត់ប្រាណ។

កៈ
អាចារ្យឥឡូវជីវិតរបស់លោកពូបានរៀបរាប់ច្រើនខ្លាំងមែនទែនប៉ុន្តែឥឡូវនិងមួយទៀតអត់ទា

ន់បានលម្អិតអំពីប្រវត្តិនៃជំនាន់ប៉ុលពតដោយសារជំនាន់ប៉ុលពតចង់ឲ្យនិយាយមកដើម្បីកូនខ្មែរនិងលោកពូណាស់កុំឲ្យថាកុំឲ្យថាវាជាសង្គ្រាមមួយដែលគេហៅថាជាសង្គ្រាមប្រល័យពូជសាសន៍ ពូណាស់សម្លាប់គ្នាឯងឯអញ្ចឹងអញ្ចឹងលោកពូអាចនិយាយឲ្យបានក្បោះក្បាយអំពីជំនាន់ប៉ុលពតតាំងពីឆ្នាំ 75 រហូតដល់ឆ្នាំ 79( 1975 1979)តើជីវិតរបស់លោកពូជួបរឿងអ្វីខ្លះតើលោកពូអាចនឹកស្រមៃឡើងវិញហើយនិយាយឡើងមកឲ្យអស់មកលោកពូ?

ខ៖
អាហ្នឹងពេលអានិងនិយាយពីជំនាន់ប៉ុលពតមែនទេ?ក៖ចាំ!!ខ៖ជំនាន់ប៉ុលពតដូចជាលឺខ្ញុំនិយាយថារត់ឡើងលើៗចឹងទៅកាលណាគេវៃគ្នាបណ្តេញយួនទៅវិញ!!!
បានចុះទៅនៅនៅបានពីរបីខែរត់ឡើងវិញមកទៀតហើយ!!!រត់មើល!!មួយឆ្នាំពីរឆ្នាំរត់ប៉ុន្តែរហូតឆ្នាំ 77ឆ្នាំ 78( 1977 1978) រត់រហូតចុងចុងឆ្នាំនិង!!

ក៖ តើលោកពូការងាររបស់លោកពូនៅក្នុងជំនាន់ប៉ុលពតគេអោយលោកពូធ្វើអ្វីធ្វើអ្វីវិញ?

ខ៖ កងចល័ត។

ក៖ កងចល័តនិងគេឱ្យធ្វើអ្វីទៅលោកពូ?

ខ៖ វាអោយជីកប្រឡាយជីកនេះដែលធ្វើស្រែធ្វើនេះអញ្ចឹងទៅហើយស្រែនៅក្នុងជំនាន់និង!! ស្គាល់រហាត់ទឹកទេ?

ក៖ ការស្គាល់?

ខ៖ ជាក់រហាត់ទឹកនេះអញ្ចឹងទៅ ហើយពេលនេះនឹងទឹកហែលទឹកស្រែកខេត្តទី 10 ខែទី 11 និងទឹកស្រែកហើយអាហ្នឹងគេឲ្យកាត់ស្មៅកាត់អី អញ្ចឹងទៅអោយវាបណ្តែតតាមទឹកទៅ!!

ក៖ 1ហិចតាពេលនឹងធ្វើបានច្រើនច្រើនទេលោកពូ?

ខ៖
ជំនាន់ហ្នឹងធ្វើច្រើនដែរផលប៉ុលពតប្រើអោយធ្វើតែអត់ប្រើថ្នាំជាដូចឥឡូវស្រូវពីដើមល្អណាស់។

ក៖ ការនិយាយទៅដឹងតែបានផលមកតែម្តងលោកពូណោះ?

ខ៖ បាទ!!ធ្វើបានផលខ្លាំងណាស់!!!

ក៖ ហ្នឹងហើយលោកពូដឹងទេថាពេលបានផលនិងមកគេយកទៅឯណាវិញពូកហ្នឹង?

ខ៖ គេដាក់តាមកង់តាមសហករណ៍អីអញ្ចឹងមីអូនសហករណ៍គេដូចថាខ្ញុំនៅតែក5 អញ្ចឹងទៅណាមួយធំៗចឹងមាន 5 សហករណ៍អញ្ចឹងណាស់នឹងទៅដល់ហើយមានជង្រុកគេធំៗណាស់!!ជង្រុកគេនិយាយពីធ្វើវិញនិយាយពីទទឹងវែងវែង50ម៉ែត្រអញ្ចឹងអីប៉ុន្តែដល់ពេលហើយឲ្យគេអាល័យជំនាន់និងគេហៅអាឡានអាបែនអាបែននិងកង់ 16 ណាស់ប្រវែងអាកុងន័រយើងឥឡូវហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ ដឹកចេញទៅមិនដឹងដឹកទៅណាទេអាខ្លះកាលនឹងគេដឹកគេថាវាទៅឲ្យទ័ពអីស៊ីអឺចឹងទៅណាស់តែមិនដឹងគេដឹកយកទៅណា!!!អត់ដឹងដែរពេលគេដឹកចេញអញ្ចឹងទៅមួយថ្ងៃមួយថ្ងៃយើងតែឡាននឹងដឹកចេញទៅ!!

ក៖ ចាំហើយមួយៗ ធ្វើទៅអត់បានហូបអញ្ចឹងឃើញតែគេដឹកចេញអញ្ចឹងទៅលោកពូណេះ??កំសត់ណាស់លោកពូអារម្មណ៍ពេលជំនាន់ហ្នឹងវាយ៉ាងណាទេលោកពូ??

ខ៖ និយាយពីពេលជំនាន់ហ្នឹងវាអស់កន្លែងនិយាយហើយ!!

ក៖ ក្នុងចិត្តគិតហើយប៉ុន្តែអត់ហ៊ាននិយាយមកខាងក្រៅមែនទេលោកពូពេលហ្នឹង?

ខ៖ និយាយស្លាប់និយាយស្លាប់យើងនិយាយអត់បានទេ!!

ក៖ តវ៉ាមិនបានទៀត!!

ខ៖ ហ្នឹងហើយមនុស្សជំនាន់ហ្នឹងវាំតែគេថាប៉ុន្តែថាផ្លែម្ទេស 1 ស្លាបព្រាមួយបាក់មិនបានផងគេយកវៃចោល។

ក៖ ទោសវាសាហាវម្លេះលោកពូ??

ខ៖ ទាំងកុមារទាំងយុវជនទាំងយុវនារីតែហើយបើគេយកឪពុកម្ដាយរបស់យើងទៅណាស់នៅកងចល័តនិងក៏គេយកទៅដែរគេថាយកទៅអប់រំ!!!អប់រំបាត់ហើយ!!

កះ គេយកទៅទាំងខ្សែតែម្ដងមែនទេលោកពូ?

ខះ បាទ!!!គេយកទៅឧទាហរណ៍គេចាប់យកឪពុកម្ដាយទៅទៅមុនៗចឹងហើយគេដឹងថានៅឯណាគេស្រាវជ្រាវនៅទ័ពនៅធ្វើទ័ពក៏គេស្រាវជ្រាវទៅចាប់ដៃរខ្លាំងណាស់ពួកហ្នឹងសម័យប៉ុលពតនិង!!

កះ គេថាជីកស្មៅជីកទាំងឫសមែនទេលោកពូ?

ខះ បាទ!!!បងជីដូនមួយគេយកឪទៅសម្លាប់គេស្រាវជ្រាវ គេដកឲ្យយកទៅនៅក្រោយហើយពេលមុនធ្វើធំដែរជំនាន់ហ្នឹងបើគិតពីឥឡូវវិញពីសក្ដ័ 5 ហើយ!!!ប្រធានកងពលហើយអាហ្នឹង!!

កះ ចានឹងហើយដូចជាពួកខ្ញុំរាល់ថ្ងៃអញ្ចឹងនេះហិពូរបស់ខ្ញុំក៏ធ្វើឡើងដល់ចៅហ្វាយខេត្តរងហើយអញ្ចឹងណាស់!!

ខះ បាទបាទ!!!

កះបើសិនជាដល់ជំនាន់ឥឡូវនិងវិញណាស់របៀបថាប្រៀបធៀបមកឥឡូវហ្នឹងវិញគេស្រាវជ្រាវដឹងថាពួកខ្ញុំងាប់អស់រលីងតែម្ដង!!

ខះ កាលនឹងវាអញ្ចឹងបាទ!!

កះ អូយ!! ទាំងខ្សែគេថាជីកស្មៅជីកទាំងឬស!!

ខះ អត់បានទេពេលជំនាន់និងកុំថាក្មេងប៉ុណ្ណឹងនិងក្មេងប៉ុណ្ណាក៏គេមិនទុកដែរ!!

កះ រត់ទៅណាក៏មិនកើតដែរលោកពូមានទេ?

ខះ រត់អត់រួចទេ ។

កះ ហ៊ី សាហាវណាស់លោកពូអើយ!! លោកពូឥឡូវយ៉ាងម៉េចដែរនិយាយរៀបរាប់អំពីការហូបចុកវិញការហូបចុករបស់លោកពូ?

ខះ ហូបចុក!! ជំនាន់និងលោកកាលពីពេលដែលខ្ញុំ នៅកងចល័តអង្គរ 1 កំប៉ុង12 នាក់បបរបបរទឹកភាវ ហើយយើងចេះតែទៅធ្វើការបេះបន្លែអីផ្សំអ៊ីចឹងទៅ។

កះ ចេះតែហូបឲ្យបានពេញពោះទៅមែនទេលោកពូ?

ខ៖ ចេះតែហូបអោយពេញៗពោះទៅ!!!

ក៖ ជាតិជូរអីមានទេលោកពូ?

ខ៖ ខ្លាំងយូរយូរដាច់ពោះស្លាប់បាត់ទៅ!!ស្លាប់អោយពព្រុយស្លាប់រាល់តែថ្ងៃ!!នៅនៅកងមួយគ្នានៅកងមួយ។

ក៖ តែមានបន្លែបេះបោចម្ជូបអញ្ចឹងទៅក៏អត់មានអីដែលមានទេលោកពូ?

ខ៖បន្លែនិងជនការប្រធានកងនារីស្លូតទៅយើងបានហូបអត់អីទេគេអាចឃើញយើងយកមកស្លមកំដៅលាយតើអាបពេលគេអោយមកនិងដាក់លាយដាក់អីទៅគេចាក់ចោលអោយហូបទេសាហាវណាស់ជំនាន់និង!!!

ក៖ ពួកនឹងអាក្រក់ណាស់លោកពូ!!

ខ៖ ហើយសុទ្ធតែគ្នាឯងគ្មានអ្នកណាទេ!!

ក៖ មិនដឹងកាំពីយ៉ាងណាទេលោកពូអើយ!!

ខ៖ បាទ!!

ក៖ នរកនរកចំតែម្តង!!!

ខ៖ពួកមីអស់ហ្នឹង!!នារីនារីវណ្ណៈគិតទៅមួយគ្រួសារក្មេងមួយមិនទាន់ចាស់អង្គុយធំលេងហ្គីតាបល្ល័ង្កលើអញ្ចឹងគេយកកាំបិតទ្រពីក្រោមក្មេង!!

ក៖ គាត់និងជាអ្នករាយការណ៍មែនទេ?

ខ៖ គាត់អ្នករាយការណ៍គេណាស់សម្រាប់ផ្ទាល់ខ្លួនគេ។

ក៖ អូយតែគាត់នៅដល់ឥឡូវហ្នឹងមែនទេលោកពូ?

ខ៖ នៅតែនៅកវេទនាដែរស្រុករបស់ខ្ញុំស្លូតណាស់ចង់អ្នកណាធ្វើអីធ្វើទៅចង់អាណាធ្វើទៅកម្មពៀរបស់គេ។

ក៖ ចាឥឡូវអ្នកដែលអ្នកមីងមួយនឹងឈ្មោះអីគេវិញ?នារីវណ្ណៈ?

ខ៖ វណ្ណៈ!!!

កះ ចាំ!!តែឥឡូវ!!

ខះ គេហៅថានារីវណ្ណនិងនារីឃុំណាស់ដល់តែអីលូវគេហៅប្រធានឃុំប្រធាននារីឃុំអញ្ចឹងទៅ!!

កះ ហើយអត់មានអ្នកណាគេទៅលើរឿងដែលលោកពូណោះ??

ខះ សាហាវណាស់ចំនាន់ពួកអស់នេះ!!

កះ អូយ មានដែលនឹកឃើញថាធ្លាប់រាយការណ៍ៗចឹងអោយមនុស្សដូចថាពេលរាយការណ៍ឲ្យសម្លាប់ក្មេងអញ្ចឹងទៅលោកពូណោះ??

ខះបាទ!!

ក ះដែលនឹកឃើញថាអញ្ចឹងណោះ ដែលនឹកឃើញទេលោកពូ??

ខះ អីទេគ្មានអ្វីទេក្ររហេមរហាមគ្មានអ្វីហួបពិបាក!!

កះ បានប្តីទេ?

ខះ បាទ មានដែនដីគេរៀបអោយជំនាន់ប៉ុលពតប្តីរបស់គាត់តែឥឡូវគេធ្វើទ័ពត្រូវពិការ ត្រូវគ្រាប់ក៏ពិការដែរប្តីរបស់គាត់ស្លូតទេ!!!អត់អីទេ!!

កះ អូយ!! តើលោកពូខ្ញុំគិតថាអាហារធ្វើបាបគេលោកពូអស់ចាំបាច់ទៅជាតិក្រោយជាតិណាជាថ្មីទេឃើញនៅលើហ្នឹង!!

ខះ បាទបាទ!!

កះ របៀបថាកុំគិតថាធ្វើបាបគេហើយ រួចខ្លួនឲ្យសោះអារឿងអយុត្តិធម៌និងត្រូវបំពេញ!!

ខះ ប៉ុន្តែក្រៅពីស្រុកខ្ញុំដូចមួយប៉ែកខាងស្រុកខ្ញុំដែរប៉ុន្តែទៅម្ខាងៗត្រពាំងអណ្តើកខាងអីនោះអោយតែពួកឯងត្រឹមប្រធានភូមិប្រធានក្រុមអីកងអីដើម្បីកអត់បានដែរ!!

កះ សម្លាប់ចោល!!

ខ៖ សម្លាប់ចោលអស់ប៉ុន្តែស្រុកខ្ញុំវិញអត់អីទេស្លូត!!!ឯងធ្វើយ៉ាងម៉េចធ្វើទៅតាមដំណើរបុណ្យបាបរបស់ឯងៗចឹងស្រួលម្យ៉ាងដែរមីអូន!!!

ក៖ ចាវាមួយយ៉ាងដែលបានដែរពេលណាដោយសារបងប្អូនគេឥវ៉ាន់លោកពូឃើញយកទៅសម្លាប់ចោលទាំងសិនសុខពេជ្រណាស់ណាស់លោកពូណាស់ហើយឡើងចឹងនឹងអាលបានដៃវិញសងសឹកវិញអញ្ចឹងហើយតែបើខ្ញុំ!!

ខ៖អាពេលចងពៀរនឹងវាមិនងាយទេហើយធ្វើយ៉ាងម៉េចកាលពីជំនាន់និងបើគ្នាមិនធ្វើអីចឹងយកគ្នាទៅសម្លាប់ចោលដូចតែគ្នា!!

Commented [j1]:

ក៖ ហ្ន៎ ទាល់តែខ្លាំងមែនទេលោកពូ?

ខ៖ ហ្នឹងហើយទាល់តែខ្លាំងហើយដល់ហើយចំនាំមើលទៅដូចតែប្រធានកងប្រធានអីប្រធានឃុំអីសម្រាប់តគ្នាគ្នារហូតវគ្គចុងអស់ហើយមើលឃុំរមេញខ្ញុំមើល មើលដំបូងតាសៀក តាសៀកហ្នឹង មកពូមន បងអាចារ្យកែមអាចារ្យកែមហើយមកសូត្រ និងសម្លាប់ដល់កគ្នារហូតហ្នឹងដដែលមួយណាទេធ្វើទ័ពគេឲ្យធ្វើប្រធានភូមិ ពួកអាតាតានោះ គេសម្លាប់ចោល។

ក៖ និយាយទៅសាហាវណាស់!!

ខ៖ អាមេកងអាមេភូមិអាមេភូមិកាលពេលនឹងគេហៅតែមេកងណាស់មេកងមេកងគេវៃគ្នាគេសម្លាប់ចោលអស់។

ក៖ តាមពិតណាស់លោកពូសុទ្ធតែមានល្បិចអីបង្កប់នៅក្នុងហ្នឹងហើយគេសំលាប់តតគ្នាអញ្ចឹងនោះទាល់តែថាធ្វើការងារនិងបានសម្រេចក៏ដោយធ្វើល្អឬមិនល្អក៏ដោយក៏ត្រូវតែយកទៅសំលាប់ទាល់តែមានចឹងដែររហូតដែររបៀបថាដូច!!
អូយពិបាកនិយាយណាស់ណាស់លោកពូដូចរបៀបថាត្រូវតែធ្វើយ៉ាងម៉េចសម្រាប់ខ្មែរឲ្យបានតែម្តងលោកពូទូកអ្នកនឹងធ្វើការល្អដូចជាបើសិនគេធ្វើការល្អគឺថាសម្លាប់មនុស្សបានច្រើនមែនទេអូនណោះ អ្នកអាចចេញទៅជាអញ្ចឹងទេ?

ខ៖
ថាពេលជំនាន់ហ្នឹងខ្ញុំនិយាយទៅវាមិនដឹងជាអ្នកណាគេអ្នកណាអ្នកដឹកនាំអត់ដឹងដែរឮតែគេថាប៉ុលពត ប៉ុលពត!! មីអូនឯងអត់ដែរស្គាល់ប៉ុលពត!!

ក៖ ខ្ញុំមិនដែលឃើញទេឃើញតែរូបថត!!

ខ៖ សួរតែម្ដាយអូនឯងថាស្គាល់ប៉ុលពតដែរឬទេលឺតែឈ្មោះអញ្ចឹង??

ក៖ អត់អត់!!ហ្នឹងហើយ!!

ខ៖
ហើយធម្មតាអ្នកដាក់អ្នកដឹកនាំប្រទេសគេត្រូវមានរូបថតហើយជំនាន់ណាក៏ដូចជំនាន់ណាដែរចំណូលសម្ដេចតាជំនាន់ណាមកក៏មានតែពេលជំនាន់នេះគ្មានទេអត់មានទេមានតែឈ្មោះប៉ុលពត!!

ក៖ ឮតែតើឈ្មោះហ្នឹងតែម្ដងមែនទេលោកពូ?

ខ៖ លឺតែឈ្មោះប៉ុលពត អញ្ចឹង!!

ក៖ សាហាវណាស់លោកពូអើយលោកពូដែលធ្លាប់??

ខ៖ ប៉ុន្តែសម្ដេចតាក៏គេយកដាក់គុក!!

ក៖ ចាណាស់ហើយប៉ុន្តែពេលហ្នឹងបានចេញទៅក្រៅហើយមែនទេលោកពូ?

ខ៖ ហេអត់ដឹងដែរខ្ញុំ ពេលជំនាន់និងគាត់ឮគេថាគេយកដាក់គុកឲ្យគាត់នូវអឺងដាក់បាយអោយបាយអោយអីអញ្ចឹងទៅការពេល 79 គាត់មក(1979) គាត់សាមញ្ញគាត់មានប្រសាសន៍អញ្ចឹងដែរសម្ដេចតា!!

ក៖ អាណិតគាត់ណាស់សុទ្ធតែ និយាយទៅអាណិតប្រជាជនខ្មែរយើងពួកគាត់ទាំងអស់និងលោកពូណាស់លោកពូមានដែលឃើញគេយកទៅសម្លាប់ចោលដែរឬទេ?

ខ៖ ខ្ញុំមិនដែលទៅទេខ្ញុំមិនបាននៅនិងភូមិព្រោះអីខ្ញុំចេញមកក្រៅទៅលើតែក្រៅក្រៅនិងកងចល័តអញ្ចឹងយើងត្រូវការតែជីប្រលាយឯណាខេត្តណាខេត្តណាសំខាន់និងគេយកយើងទៅៗចឹងទៅទៅទៅ ដើរទេវាមិនឲ្យជាទេ ដើរ!!

កៈ ការចុះលោកពូនៅក្នុងក្រុមនិងដូចរបៀបថាបើសិនជាអ្នកណាគេអត់មានពូបានគេចាប់យកទៅហ្នឹងតែម្តង?

ខៈ មាន ហើយបងមួយណាមួយនោះដូចនៅក្រុមខ្ញុំអញ្ចឹងកំពុងតែជាប្រឡាយប្រឡាយគេយកម៉ែឪទៅសម្លាប់ចោល គេមកយកហើយមានមួយស្រី ក្មេងហ្នឹងយកទៅសម្លាប់ទៀត!!

កៈ ពោះ អីគេលោកពូពោះធំមែន?

ខៈ និងនេឈ្មោះប្រុសឈ្មោះឡឹក ។

កៈ ហ្អូជេរ្យងទេ!!

ខៈ តែឈ្មោះហឺ!!

កៈ ចាំ!!ហៅទៅពុំដឹងហើយមែនទេតែយកទៅបាត់ហើយមែនទេ?

ខៈ ទៅបាត់រហូតហើយ ។

កៈ ចាំ!!រដឹងតែស្លាប់ហើយ!!

ខៈ ថានេះគេថាយកទៅរៀនសូត្រអោយគេរៀនសូត្រ។

កៈ កម្រណាស់ថាមកវិញ!! មិនងាយទេ!!

ខៈ អានេះគេអោយយកទៅរៀនសូត្រហេតុកូនឆ្លបកគេទូចទូច!!

កៈ ចា!!មកយកទៅនឹង

ខៈ កាលពេលនឹងដូចជាខ្លាចណាស់ឆ្លបកពេលនិងទូចទូច ពួកវាសាហាវណាស់នេសាគេនេសាគេឃុំនឹងគេមកហើយយើង ចេះតែទៅតាមគេហើយ។ជំនាន់និងខ្ញុំរកមិនដឹងយ៉ាងម៉េចខ្ញុំឆ្លល់ជំនាន់នោះហើយទៅ!?

កៈ វាដូចជារបៀបថា បណ្តុះគំនិតណាស់!!

ខៈ ជណ្តើរឈើមួយកន្លែងៗចឹងតែគ្មានអនាគតទេគ្មានអ្នកណាមានអីទេគ្មានទេមានតែអ្នកភ័យខ្លាចថាមិនដឹងថ្ងៃណាគេមកយកយើងទៀត!!!

កៈអត់ដឹងមូលហេតុពេលខ្លះមកយកដោយអត់ដឹងដូចជាការរស់ចាំតែភ័យរហូតលោកពូនឹងមែនទេ?

ខៈ
បាទ!!ដឹងតែមួយថ្ងៃមួយថ្ងៃនឹងដឹងតែភ្លេងពេលដេកកុំភ័យដេកនិងមិនសូវបានឯណាប៉ុន្មានទេពេទ្យរលត់ធ្វើតធ្វើដល់ម៉ោង 10រឺម៉ោង 11 ហើយតែមក 3 ម៉ោង 3 ម៉ោង 4 ចាប់ឡើងហើយធ្វើទៀត។

កៈ ដេកក៏មិនបានគ្រប់មូបមិនបានគ្រប់ ពិបាកណាស់លោកពូ។

ខៈ ប្រឡាយ គេចាប់ធ្វើអ្វីយ៉ាប់ណាស់ធ្វើការនៅកងចល័ត!!

កៈ លោកពូម្នាក់ដែលរួបពីជំនាន់នឹងមកសុទ្ធតែជាជីវិតមួយជីវិតពេជ្រហើយ!!

ខៈអោយតែខ្ញុំមិនដឹងមិនចង់បានអីអត់ចង់បានអីអោយតែបានជីវិតនៅរស់អោយតែបានសុខប៉ុណ្ណឹងខ្ញុំអស់ហើយខ្ញុំនិយាយត្រង់តែម្តង។

កៈ ក្សត្រងគ្នាដែលៗបំផុតហើយលោកពូណោះ?

ខៈ ថ្លៃណាស់។

កៈ ទាំងឪពុកទាំងម្តាយខ្ញុំយាយតារបស់ខ្ញុំ!!

ខៈ
មនុស្សម្នាក់ម្នាក់មិនបាច់ទេចាស់ៗជំនាន់និងគ្រាន់តែម្នាក់នោះម្តាយរបស់ខ្ញុំមិនដឹងទៅប៉ុន្មានដងបន់អោយតែបានរស់កុំចៅរស់ សុខសប្បាយទាំងរអស់គ្នា!!

កៈ អូយ!!អាណិតណាស់លោកពូ
លោកពូនៅក្នុងជំនាន់ពពត់កន្លែងណាដែលលោកចងចាំបំផុតជាងគេតើលោកគិតថាភ័យហើយរន្ធត់នៅក្នុងចិត្តជាងគេ លោកពូចាំកន្លែងណាជាងគេ?

ខៈ កន្លែងហាត់និងកន្លែងកងចល័តនិង ជីកប្រឡាយ ម្នាក់ឯង 12 ម៉ែត្រ។

កៈ ហើយជ្រៅទេលោកពូ?

ខ៖ ជី របស់គេនឹង បានកន្លះម៉ែត្រកន្លះម៉ែត្រចាក់!! អ្នកណាជាងហើយអញ្ចឹងទៅអ្នកណាគេមានកម្លាំងគេជីកលឿនៗចឹងទៅចៃចំណែកខ្ញុំមិនសូវមានទេអត់មានកំលាំង!!

ក៖ តែបើសិនជាអត់ហើយ?

ខ៖ បើសិនជាអត់ហើយ គេឲ្យយើងធ្វើបង្ហើយទាល់តែហើយ!!

ក៖ ហើយឡើងមហែបៗ?!!សូម្បីតែឥឡូវនេះខ្ញុំហូបបាយថ្ងៃត្រង់ហើយហើយឥឡូវខ្ញុំកូរពោះទៀតហើយនេះថាខ្ញុំមានអារម្មណ៍ថាខ្ញុំមិនសូវមានកម្លាំងច្រើនហើយចុះទំរាំតែអត់អត់បានហូបអញ្ចឹងទៅហើយទៅធ្វើការតែខ្លួនចង់ឃ្លានយ៉ាងម៉េចទៅលោកពូ??

ខ៖ ធ្វើតក់ៗទៅគេ!!

ក៖ ដល់កហើយ។

ខ៖ យើងធ្វើមិនហើយជូនកាលគេបន្ថែមឱ្យបន្ថែមឲ្យលើសហ្នឹងទៀត។

ក៖ ហ្អ!! ដើម្បីអោយ យើងមានចិត្តធ្វើអោយហើយ។

ខ៖ ហើយបើសិនជាអ្នក ធ្វើលឿន អោយដាក់រឹតតែច្រើនឡើងច្រើនឡើងពេលធ្វើគេមានក្រុមរបស់វាមួយក្រុមមួយក្រុមដើម្បីអ្នកធ្វើទៅខ្លះ៥
នាក់ខ្លះមួយក្រុម១២នាក់!!ដាក់អញ្ចឹងទៅអត់ទៅដាក់អោយនៅម្នាក់ឯង!!

ក៖
ចាំ!!និយាយទៅបងប្អូនរបស់លោកពូក្រុមគ្រួសារអីមានអ្នកស្លាប់ដែលនៅក្នុងជំនាន់ប៉ុលពត?

ខ៖ មានតែអំហើយនិងពូ!!

ក៖ គេទៅសម្លាប់ចោលមែនទេលោកពូ?

ខ៖ ពោះជាមួយម្ដាយរបស់ខ្ញុំម៉ែរបស់ខ្ញុំបទស្រីទាំងអស់ហើយប្រុសមួយតែពូខ្ញុំដណឹងគេយកគេជម្លៀសឲ្យមកនៅកំពង់ស្ពឺគាត់នៅរស់គាត់ទើបតែស្លាប់តែកូនចៅគាត់នៅកំពង់ស្ពឺនិង!!!

ក៖ចាំ!!

ខ៖ ឡើងដែលរស់ជាមួយម្ដាយរបស់ខ្ញុំនិងពូខ្ញុំហើយពីមុំខ្ញុំគេយកទៅសម្លាប់ចោលទាំងអស់ ភូមិប៉ុន្មាននាក់ហ្នឹង!!

ក៖ ចាំ!!

ខ៖ ប៉ុលពតយកទៅសម្លាប់ចោលទាំងអស់លើរស់តែឪពុកខ្ញុំមួយទេ ឪពុករបស់ខ្ញុំសឹងតែគ្មានព្រលឹងដែរ!!!
ហើយឪពុករបស់ខ្ញុំនិងម្ដាយរបស់ខ្ញុំគេអត់ឲ្យនៅជាមួយគ្នាទៀតណាស់។

ក៖ ចា គេបំបែក!!

ខ៖ គេបំបែកនៅឆ្ងាយឆ្ងាយពីគ្នាទាត់មួយនៅបន្ទាយនៅជិតតាកែវព្រៃលើព្រៃលើ ស្គាល់មីអូនឯងស្គាល់ព្រៃលើដែរឬទេ?

ក៖ ស្គាល់ស្គាល់ព្រៃលើនៅបាទីនិងមែនទេលោកពូហោ?

ខ៖ បាទ!!

ក៖ ហ្នឹងហើយស្រុកម្ដាយឪពុករបស់ខ្ញុំនៅទន្លេបាទីនឹងលោកពូ!!

ខ៖
ហ្នឹងហើយគេឲ្យមកនៅភូមិចំការធ្វើអីនៅទីនោះថៃម្ដាយរបស់ខ្ញុំគាត់នៅក្រុមដែលនារីនារីសហករណ៍អញ្ចឹងធ្វើការគេមានក្រុមរបស់គេដែរដកស្ទូងលើកទំនប់លើកបន្លាយអញ្ចឹងទៅ!!

ក៖ នឹងមានគេអញ្ចឹងទៅ!!

ខ៖ យ៉ាប់ណាស់ជំនាន់ហ្នឹង!!

ក៖ លោកពូបន្ទាប់ពីបែកជំនាន់ប៉ុលពតលោកពូមានអារម្មណ៍យ៉ាងម៉េចដែរលោកពូ?

ខ៖ ពេលបែកមាត់យើងបាននៅមូលបងប្អូនមូលបងហើយដល់ពេលនេះទៅផ្លាស់គ្នាបែកទៅខ្លះមិនដឹងកំសត់ដល់ថ្នាក់ណា
ខ្លះនៅតែម្នាក់ឯងអញ្ចឹងទៅម៉ែឪឲ្យស្លាប់អស់ហែជំនូននិងខ្លះខ្ញុំឃើញម្នាក់នេះក្មេងអាយុ 7 8 ឆ្នាំជំនាន់និងហើយមកដល់ម្ដាយស្លាប់
អស់ហើយក្មេងជំនាន់និងសិទ្ធិតែនៅមិនមែននៅជាមួយម្ដាយទេអូនណាស់នៅតាមកងនៅតាមនេះរបស់គេណាស់ហើយដល់ពេលរត់ទៅរត់ទៅវាបែកគ្នាខ្លះស្លាប់ម្ដាយអស់ឯងចឹងទៅ!!

កៈ អូយ លោកពូអើយកម្សត់ប៉ុណ្ណាទៅ!!

ខៈអាខ្លះទើបតែប៉ុន្មានឆ្នាំខែ ខ្លះទើបតែមិកគ្នាឃើញផងបាទបាក់បែកគ្នារត់បែកគ្នាអាខ្លះប្រឹងប្រែងទៅរកក៏ឃើញទៅ ខ្លាក៏មិនឃើញខ្លាបានរត់ទៅក្រៅ។

កៈ ចាំ!!លោកពូស្រមៃមើលមើលបែកពីសង្គ្រាមមកមកស្រុកមកទេសហើយបងប្អូនស្លាប់ចោលអស់រលីងនូវតែខ្លួនឯងម្នាក់ឯងនេះអារម្មណ៍មិនដឹងស្រណោះប៉ុណ្ណាទេពេលហ្នឹងអាណិតណាស់!!

ខៈ ហើយជំនាន់ពួកហ្នឹងនិយាយរួមទៅតែងតែជំនាន់និងខ្ញុំជាខ្ញុំមិនទាន់គ្រប់អាយុអាយុ 15 ឆ្នាំឲ្យធ្វើទ័ពប៉ុលពត!!

កៈ ទព័ទៀត!!!

ខៈ ទ័ព។

កៈ បើមើលទៅរាងទ្រង់ខ្លាំងគេអោយធ្វើទព័ហើយមែនទេលោកពូ?

ខៈ បាទ!! ខ្ញុំមកនៅពេលប៉ុន្មាននេះខែទៀតយួនរត់ត្រូវឈ្មោះអ្នកអោយទៅធ្វើទ័ពទៅវាយយួនដែរទេតើកាលពីពេលនឹងចូល 15ឆ្នាំ!!

កៈ ហ្វឹកហ្វឺនតែបន្តិចបន្តួចហើយទៅបណ្តោយ!!

ខៈ បានហើយដោយចូលទៅបាននេះទៅយួនចូលទៅបានរស់វិញ ។

កៈ ការនិយាយទៅបានល្អកន្លែងហ្នឹងដែរមែនទេលោកពូ?

ខៈ បាទបាទ។

កៈ លោកពូផ្ទះជំនាន់លន់នល់កាលពីជំនាន់លន់ណុលម៉េចដែរឃើញទំលាក់គ្រាប់អីដែរឬទេ ?

ខៈ ឃើញពីជំនាន់លន់នល់ ឃើញខ្លះទំលាក់ឃើញខ្លះស្លាប់ខ្លះ ស្រុកខ្ញុំឯណោះទម្លាក់មកខ្លះអាមិច គេហៅអាមិចនិងទំលាក់គ្រាប់បែកពីក៏បានពីកប៉ាល់ហោះជម្រៅវាជ្រៅណាស់វាប្រហែលជា 4 5 ម៉ែត្រ ជម្រៅ 1 គ្រាប់ 1 គ្រាប់របស់វាជ្រៅណាស់!!ហើយរណ្តៅ របស់វាមានប្រហែលជា 30 ម៉ែត្រ ជុំវិញតែម្តង មូលមូល

រណ្ដៅរបស់វា គ្រាប់របស់វាៗប៉ុននេះ!!ហើយ បើអាបេ អាបេ៥២ អាបេកងឌីច ទំលាក់ខ្សែមួយខ្សែមិនដឹងប៉ុន្មានទេ។

កៈ ឃើញទាំងខ្សែទាំងខ្សែៗចឹងតែម្ដងលោកពូ?

ខៈ ទម្លាក់មក ផ្ទៀងមកមួយខ្សែមួយខ្សែមិនដឹងប៉ុន្មានទេ អាហ្នឹងទន្លាក់ច្រើនតែនៅលើភ្នំ ទម្លាក់តាមភ្នំ។

កៈ ទម្លាក់ដើម្បីឱ្យត្រូវទ័ព!!

ខៈ ពេលវាមកទម្លាក់ម្ដងម្ដងមិនចេះមួយគ្រឿងទេ4 5 គ្រឿង។

កៈ ហើយចំផ្ទះប្រជាពលរដ្ឋឥវ៉ាន់ដែលលោកពូមែនទេ?

ខៈ បាទ??

កៈ ចំផ្ទះប្រជាពលរដ្ឋដែរឬក៏អត់?

ខៈ ហ៊ឺ!!តែចំអ្វី អ្វីក៏នៅតែចំនេះក៏មិននៅចាំអីក៏មិនដឹងដែរ!!កៈចា!! ខ អីក៏មិនដឹងដែរ។

កៈ តែលោកពូពេលនិងនាំគ្នាទៅទីណា ធ្លាក់ចំភូមិស្រុកលោកពូដែរទេ?

ខៈ កាលពីរជំនាន់និងជំនាន់និងជំនាន់លន់ណល់ ខ្ញុំអត់ រត់ទេ។

កៈ នៅតែផ្ទះនិងពេលមែនទេលោកពូ?

ខៈ នៅផ្ទះប៉ុន្តែ ផ្ទះមួយៗសុទ្ធតែត្រង់សេគេហាត្រង់សេ ធ្វើដើមចេកដើមគរដៃដាក់នៅលើដំបូលទៅខ្លះធ្លាក់ចំៗចឹងទៅស្លាប់ទាំងអស់អញ្ចឹងទៅ ទម្លាក់ចំអាត្រង់សេនិង។

កៈ កស្លាប់អញ្ចឹងទៅ។

ខៈ វេទនាណាស់មីអូនអើយ!!ជំនាន់ហ្នឹងហើយឲ្យតែកើតសង្គ្រាមនិងក្មេងក្មេងស្រករមីអូនឯង ឲ្យទៅសែងគ្រាប់គ្មានបានសុខលុយឥឡូវទេ!!ឥឡូវបាត់ប្រទេសសុខ ធូរហើយ!!

កៈ ចានឹងហើយ!!

ខៈ ចេះតែនាំគ្នារកស៊ីកូនចៅអោយតែសុខកុំអោយតែសង្គ្រាម កើតសង្គ្រាមទៅ វាមិនងាយជាពិបាកណាស់ គ្មានបានជួបមុខមូលគ្នាអីទេ។

កៈ ហ្នឹងហើយគ្រាន់តែលោកពូបានប្រាប់ពីបទពិសោធន៍ក្នុងជីវិតរបស់លោកពូប៉ុណ្ណឹងខ្ញុំដឹងថាវាពិបាកយ៉ាងម៉េចហើយខ្ញុំគិតថាខ្ញុំការអត់ទោសមែនប៉ុន្តែខ្ញុំនៅគិតស្រមៃទៅលោកពូណាស់ហើយ ឃើញនៅក្នុងទូរទស្សន៍ឃើញអីទៀតអញ្ចឹងទៅគួរអោយខ្លាចខ្លាំងណាស់ឃើញគ្រាប់បែកឃើញការស្លាប់នៅខាងមុខនៅនឹងភ្នែកដូចគេនិយាយថាភ្នែកនៅកញ្ចឹងក លោកពូហេ?

ខៈ បាទ!! ឃើញអាខ្លះពិការរស់ពិការស្លាប់អីៗចឹងទៅខ្ញុំឃើញជាក់ស្តែងប្អូនរបស់ខ្ញុំអញ្ចឹងកំបិតស្មើស្មើនឹង!!

កៈ ចាំ!!

ខៈ យើងទាំងពីរ!!

កៈ អាណិតគាត់ណាស់លោកពូ។

ខៈ នូវរាល់ថ្ងៃនៅរស់។

កៈ អាយុថ្លៃណាស់ដែលលោកពូណោះ?

ខៈ បាទបាទ!!!ថ្លៃ!

កៈ ចាំហ្នឹងហើយលោកពូមានអីចង់រៀបរាប់អំពីជីវិតបន្ថែមទៀតតែលោកពូចាំបំភ្លេចបានណាស់ចង់និយាយប្រាប់អីទៅកូនកៅអីថែមទៀតទេ

ខៈ ទេខ្ញុំថាបើមិត្តមិត្តកុំអោយតែមានកើតសង្គ្រាមកុំអោយអារបបទាំងអស់នឹងត្រឡប់មកវិញពីបាកណាស់!!យ៉ាងម៉េចយ៉ាងម៉េចទៅកុំអោយតែអារបបហ្នឹងអារបបប្រជាធិបតេយ្យនឹងយ៉ាប់ណាស់!!

កៈ កម្ពុជាប្រជាធិបតេយ្យ មិនដឹងប្រជាធិបតេយ្យរកឪវាស្អីទេ!!

ខៈ ប្រជាធិបតេយ្យតែម្នាក់វាវាមិនមែនប្រជាធិបតេយ្យជាមួយនឹងយើងផង!!

កៈនឹងហើយកុំឲ្យវិលមកវិញមែនទេលោកពូ?

ខៈ បាទ!!

កៈ សង្ឃឹមថាវានឹងអត់មានរឿងមួយនឹងកើតឡើងម្តងទៀតសង្ឃឹមថាវាចប់។

ខៈ ថាអោយតែបានសុខបាទរហូតៗចឹងទៅ!!កុំឲ្យតែកើតសង្គ្រាមឲ្យតែអ្នកដឹកនាំធ្វើអោយកុំអោយកើតសង្គ្រាមកើតសង្គ្រាមពិបាកណាស់!!

កៈ ចាំហ្នឹងហើយ ដោយសារកើតសង្គ្រាមដោយសារតែការគិតរបស់មនុស្សដែរមួយក្រុមសោះធ្វើឲ្យមនុស្សពេញប្រទេសទាំងប្រទេសនិងរាជធានីទាំងអស់លោកពូណោះ?

ខៈ បាទ!!

កៈ អញ្ចឹងសង្ឃឹមថារដ្ឋាភិបាលសព្វថ្ងៃនឹងគិតនូវអ្វីដើម្បីបញ្ចៀសសង្គ្រាមទាំងអស់និងលោកពូណាស់ណោះ?

ខៈ បញ្ចៀសសង្គ្រាម!!ឥឡូវសព្វថ្ងៃយើងមើលសាកលលោកដូចជាប្រទេសឧត្តមប្រទេសឯណានោះទេសង្គ្រាមនោះ,!!

កៈ ចាំ!!!

ខៈ ឃើញថាខ្មែចខ្ញុំឃើញបែបនេះ។

កៈ ហ្នឹងហើយ។

ខៈ វេទនាណាស់ពេលនឹកឃើញក្នុងទូរទស្សន៍ឃើញតែភ្លើង!!

កៈ នៅប្រទេសស៊ីរីលោកពូ!!

ខៈ មានសង្គ្រាមឃើញតែនេះអញ្ចឹង។

កៈ ការនៅប្រទេសស៊ីរីសព្វថ្ងៃនិងបាញ់គ្នាឡើយលោកពូណាស់!!

ខៈបាទ!!

កៈ បងរបស់ខ្ញុំនិយាយថា 6 7ឆ្នាំហៅលោកពូនិងថៃយ៉ាងម៉េចទេខ្ញុំមើលនៅក្នុងសង្គមប្រព័ន្ធ facebook នឹងនោះលោកពូ!!

ខ៖ បាទបាទ!!

ក៖ ក្មេងម្នាក់និងណាស់ គេយកកាមេរាដើម្បីថតថ្មីនិងសោះក្មេងម្នាក់និងលើកដៃដឹងលោកពូមានន័យថាយ៉ាងម៉េចទេ?គឺមានន័យថាខ្លាចគេបាញ់អញ្ចឹងកុំចុះចាញ់ឲ្យហើយលើកដៃមុនឱ្យហើយអញ្ចឹងទៅ!!

ខ៖ វាខ្លាចស្លាប់ណាស់!!

ក៖ ហ្នឹងហើយរបៀបថាគ្នានៅទូស័ព្ទនិងលោកពូណាស់ ដូចរបៀបឃើញដែរថាសង្គ្រាមឃើញតែកាំភ្លើង
អញ្ចឹងទៅដល់ពេលគេថតដោះគិតស្មានថាកាំភ្លើងវិញសុខចិត្តលើកដៃអញ្ចឹងវិញគ្នាអត់ចង់ស្លាប់គ្នាចំនៅរស់អញ្ចឹងដែរលោកពូណាស់កំសត់ណាស់នឹកឃើញអញ្ចឹងណាស់លោកពូ!!

ខ៖ អញ្ចឹងបានតែខ្ញុំឆ្ងល់ដែរនិយាយជាក់ស្តែងដូចជាខ្មែរយើងដូចជាជំនាន់លន់ណុលអញ្ចឹងជំនាន់លន់ណល់នាំគ្នាធ្វើទាហានៗចាំតៗគ្នាមកថាទាហានលន់ណុលជា
ឈ្លើយសឹក!!យកគ្នាទៅ សម្លាប់អស់អញចឹងទៅដល់ពេលជំនាន់ជំនាន់ជំនាន់យើងឥឡូវវ៉ែឈ្មុះប៉ុលពតប៉ុន្តែអញ្ចេះអត់សំលាប់ដែរគ្រាន់តែទុកដូចបងជីដូនមួយ
គាត់ដឹងតែគេឲ្យធ្វើក្រដាសពិការតែគាតើរឹងគាត់មិនធ្វើដល់ពេលគាត់មិនធ្វើអត់បានដែរ ហើយ កំបន្ទោសរាជរដ្ឋាភិបាលមកពី គាត់ទេរឹង។

ក៖ គាត់ជាទ័ពរបស់ប៉ុលពត?

ខ៖
ពីមុនគាត់ធ្វើធំដល់តែពេលធ្វើធំហើយដឹងតែពីចាញ់គេអីដាក់ពាក្យឲ្យធ្វើដែរធ្វើក្រដាសស្នាមអីអញ្ចឹងទៅអោយប្រាក់ខែប្រាក់អីអញ្ចឹងទៅគាត់មិនព្រមធ្វើ។

ក៖ ចាំ គាត់រឹង!!

ខ៖ អញ្ចឹងមិនដឹងទៅបន្ទោសអ្នកណា។

ក៖ ដោយសារគាត់ទ័ពពលពតមែនទេលោកពូ?

ខ៖ ទ័ពប៉ុលពតចេញតាំងពីឆ្នាំ 1960!

កៈ ចាំ!! ហ្នអញ្ចឹងគាត់មានបានបម្រើកងទ័ពពេលអំឡុងសង្គ្រាមនិងដែរឬទេលោកពូ?អាសង្គ្រាមប៉ុលពតនិងណាស់?

ខៈ គាត់បម្រើសុទ្ធបម្រើដល់ពីការជើងម្ខាង។

កៈ ធ្វើមេគេដែរឬទេលោកពូ?

ខៈ មុខឡើងពិបាក!!

កៈ ធ្វើមាសសហករណ៍មែនទេលោកពូ សហករណ៍មែនទេលោកពូមេក្រុម  មែនទេ?

ខៈ គាត់មិនមែនធ្វើម៉េចក៏ចាកចេញតស៊ូតាំងពីជំនាន់តាជំនាន់ស្ដេច!!

កៈ ជំនាន់សម្ដេចតាមែនទេ?

ខៈ ជំនាន់ស្ដេចទាហានសម្ដេចតាអញ្ចិងណាស់!!

កៈ ចាំ!!

ខៈ តែដល់ពេលប៉ុលពតឈ្នះហើយគេមិនទៅទ័ពប៉ុលពត!!

កៈ ចាប៉ុន្ដែគាត់ចូលរួមនៅក្នុងហ្នឹងដែរឬទេ?

ខៈ ប្រធានគេហៅថាប្រធានកងពលតូចដែរទៅណាស់ កាលពេលមុននឹងគេហៅគាត់ធ្វើប្រធានដៃណាស់!!

កៈ តែគេដូចថាគាត់អត់សម្លាប់អត់ធ្វើអីគេដែរលោកពូហេ?? ដូចជាសម្រាប់ប្រជាជនអីនោះ!!

ខៈ គាត់មានសម្លាប់អ្វីគាត់ទៅវ៉ៃដៃយួនតែអីទេតើ អត់មានអីនេះទេទ័ពស្លូតណាស់។

កៈ អញ្ចឹងអ្នកសម្រាប់ផ្សេង?

ខៈ ទាល់តែកម្មាភិបាលកម្មាភិបាលនិងបានសម្លាប់ប្រជាជនគ្នាគ្មានដឹងថាមិនដឹងម៉ែឪគេយកទៅសម្លាប់ផង!!

កៈ អញ្ចឹងប្រចាំការតែជាមួយពួកទ័ពយួនឯណោះទេ?

ខៈ មិនដែលដឹងនៅតែនេះអញ្ចឹងទៅ!!

កៈ ហ្ហ៎ មានអញ្ចឹងទៀតខ្ញុំមិនដឹងទេលោកពូលោកពូនិយាយប្រាប់មកបានខ្ញុំដឹងនេះ!!

ខៈ ទ័ពយើងដូចជាទ្រព្យដូចតែកាលពេលរៀនថៃឈ្លោះគ្នានៅតែថៃៗចឹងទៅព្រំដែនជាប់ទ័ពទ័ពគ្នាមិនដឹងអ្វីទេ!!

កៈចាំ!!

ខៈ តែដល់តែហៅថាតែគ្នាខុស!!!ខំតស៊ូដើម្បីប្រយោជន៍ខ្មែរដែលនឹងទេតើខ្ញុំឃើញ!!

កៈ ចាំតែអត់ដឹងអារឿងផ្ទៃក្នុងណេះ!!

ខៈ ដឹងទេរឿងផ្ទៃក្នុង!!

កៈ លោកពូសម្រាប់ជីវិតរបស់លោកពូ!! ជិតចប់ហើយនៅសល់តែមិនតិចទេ!!លោកពូមានសេចក្តីសង្ឃឹមអ្វីក្នុងជីវិតដូចពេលពូចំណាស់នឹងហើយស្លាប់ជីវិតបន្ទាប់ទៀតណាស់ឈ្មោះអ្វីដែរពេលខាងក្រោយនិង?

ខៈ ហ៎ៅ!! ខ្ញុំសង្ឃឹមរាល់ថ្ងៃបើតាមជីវិតរបស់ខ្ញុំអត់មានសង្ឃឹមតែរឿងកូនឲ្យបានសុខតែប៉ុណ្ណឹងបានទឹកកូនសុខប៉ុនហ្នឹងអរគុណហើយគ្មានសង្ឃឹមចង់បានអីទៀតទេបើបានដូចរាល់ថ្ងៃយើងរស់ខ្លួនយើងយើងហូបកូនយើងមានចង់ហូបអ្វីហូបនិងដូចជាខ្ញុំចង់បង្គាអីទេទិញតែមួយម៉ឺនមកកន្លះគីឡូហូប!!

កៈចាំ!!

ខៈចង់អីហូបនិងមិនមែនដូចជំនាន់និងមានហែកគេអោយហូបទៀតមានមាសមានអ្វីគេឆែកឃើញទាំងអស់។

កៈ រៀបទៅវ៉ៃទៀតចោល!!

ខៈ គេទៅវ៉ៃ ចោលទៀតចាស់ៗ គាត់លាក់បាន!!!

កៈ លោកពូភ្លេចសួរមួយទៀតមួយជីវិតរបស់លោកពូលោកពូធ្វើការងារអ្វីខ្លះ?តាំងពីតូចរហូតដល់ចំណាស់និង?

ខ៖ ខ្ញុំអត់មានធ្វើការអីទេនិយាយថាពីជំនាន់ប៉ុលពតឲ្យនៅកងចល័តធ្វើការនៅកងចល័តនិង!!

ក៖ ចាំ អារហូតដល់បែកពីសង្គ្រាមអីអស់ហ្នឹងមកណាស់ដូចរបៀបថាឥឡូវបែកចេញពីសង្គ្រាមប៉ុលពតហើយមានប្ដីនិងប្រពន្ធមកពូធ្វើការងារអ្វី?

ខ៖ អត់ទេកាលរមកមានប្រពន្ធនិងគេអោយធ្វើអ្នកដែរនៅក្នុងភូមិនិងការពារវាមានក្រុមណាស់គេអោយខ្ញុំធុរជនក្រុមដែរ!!

ក៖ ចានឹងហើយ។

ខ៖ ប្រធានក្រុម!!

ក៖ ប្រធានក្រុមពាក្យបែកប៉ុលពតមកហើយមែនទេ!!

ខ៖ បែកពុំលពត 79នឹងណាស់(1979)!!

ក៖ចា!!

ខ៖កាលពី 79(1979)!!គេមិនរៀបក្រុម!!

ក៖ ឲ្យលោកពូមើលនៅគ្រប់គ្រង!!

ខ៖ គេឲ្យនូវប្រធានក្រុមអញ្ចឹង!!

ក៖ អញ្ចឹងលោកពូពូស្រែចម្ការដើម្បីប្រកបរកស៊ីប្រចាំថ្ងៃអញ្ចឹងទៅ?

ខ៖ ធ្វើតែស្រែ។

ក៖ តែប៉ុណ្ណឹងមែនទេលោកពូ?

ខ៖ គ្មានស្អីទេស្រុកខ្ញុំតែស្រែចម្ការទើបតែបានកូនកូនគេចេញមកធ្វើរោងចក្រធ្វើអីចឹងទៅបានមកស្គាល់ភ្នំពេញកុំអីមិនស្គាល់ទេ!!

ក៖ ឥឡូវមកទាំងប្ដីទាំងប្រពន្ធមែនទេលោកពូណោះ?

ខ៖ មកមកមិនពូថាមានចៅនិងកាបានប្រាំឆ្នាំមកនៅទីហ្នឹងបាន 5 ឆ្នាំផ្ទះរបស់គាត់ធ្វើខាងក្រោយមិនទាន់ហើយឯណា!!

ក៖ ចាំ!!

ខ៖ មកនៅ!!

ក៖ ហ្ហ៎ អញ្ចឹងយូរណាស់ហើយលោកពូណោះ!!ខ៖បាទ!! ខ៖ដោយសាររាងយូរឆ្នាំដែរហើយ!!

ខ៖ 5 ឆ្នាំ 6 ឆ្នាំដែរហើយ។

ក៖ ចាំលោកពូប្រពន្ធយ៉ាងម៉េចដែរហើយឥឡូវនិយាយថាចរិករបស់គាត់យ៉ាងម៉េចដែរលោកពូប្រពន្ធ?

ខ៖ ខ្ញុំប្តីប្រពន្ធខ្ញុំ កូនចៅពូខ្ញុំនិយាយថាពូម៉ែឪមិនដែលមាត់អីផងកូនចៅលឺឡាឡូឡាអានេះវាស្រែកវាប្រកែកប្រកែកគ្នាវានិយាយតែអញ្ចឹង
កូនចៅនាអូនឯងជឿចុះថាម៉ែឪយ៉ាងម៉េចកូនចៅៗចឹងម៉ែឪអត់ដែលឈ្លោះគ្នាកូនចៅកូនចៅក៏គ្មានឈ្លោះគ្នាដែរដឹកនាំកូនយើងតែអញ្ចឹង។

ក៖ ហ្នឹងហើយ!!!

ខ៖ តែយើងស្លូតគឺស្លូត ប្រពន្ធរបស់ខ្ញុំគាត់មានធ្វើអីទេធាត់ដើរស្ទើរតែមិនរួចផង!!ធាត់ដូចជាអំអញ្ចឹង គាត់សរទេតើគាត់សរស្អាតណាស់។

ក៖
ចានឹងហើយស្រលាញ់ហើយឥឡូវនោះចេះស្រលាញ់ហើយមិនមែនដូចពេលមុនទេលោកពូមានទេ!!
ចាំលោកពូមួយនេះគឺជាសំណុំមួយចង់ក្រោយដល់វគ្គបញ្ចប់ហើយអរគុណសម្រាប់ការផ្តល់ដូចជាការចងចាំដូចជាប្រវត្តិជីវិតរបស់លោកអូនចង់ណាស់អញ្ចឹងមួយទៀតថាតើពូមានអ្វីចង់ផ្តែផ្តាំទៅកាន់កូនចៅជំនាន់ក្រោយក៏ដូចជាជូនប្រជាជន
ខ្មែរឬក៏ដែលបានស្តាប់សំដីរបស់ពូៗចឹងណាស់ថាតើលោកចង់ប្រៀនប្រដៅមនុស្សជំនាន់ក្រោយក៏ដូចជាកូនចៅលោកពូឲ្យដើរលើផ្លូវយ៉ាងម៉េចដែរ អញ្ចឹងណាស់?

ខ៖ ខ្ញុំចង់ខ្ញុំប្រដៅកូនអញ្ចេះថា ធ្វើយ៉ាងម៉េចក៏ដោយអោយតែធ្វើល្អទៅទីណាឲ្យមានញ្ញាតិកូនកុំឱ្យទៅទីណាគេខុសអីតែយើង ក៏អត់កើតដែរ

ទៅទីណាអោយមានញាតិ កុំទៅទីណាអត់មានញាតិទៅទីណាក៏គេស្អប់ទៅទីណាក៏គេស្អប់វាមិនបានសុខទេមនុស្សយើង!!

កៈ លោកពូចង់ឲ្យពួកគាត់ជៀសផុតពីអ្វីដែលលោកពូ?

ខៈ អោយតែវាបានសុខទៅអ៊ីចឹង ។

កៈ ចាហ្នឹងហើយ។

ខៈ មិនចង់បានអ្វីទេចង់បានតែសុខ។

កៈ ចេះផុតពីអំពើដែលបំពាននិងច្បាប់ណោះលោកពូណោណះ?

ខៈ បាទ!!

កៈ ចាហ្នឹងហើយ។អញ្ចឹងអរគុណច្រើនលោកពូសំរាប់ការអោយសម្ភាសនៅក្នុងថ្ងៃនេះហើយអ្វីទាំងអស់ខ្ញុំដឹងថាកូនចៅរបស់លោកពូពួកគាត់នឹងបានស្តាប់សំឡេងរបស់លោកពូ តាំងពីតូចរហូតដល់ធំៗអញ្ចឹងណាស់!!!! ឡើងមួយជីវិតរបស់លោកពូហើយ អំបាញ់មិញដោយសង្ខេបរយៈពេលមួយម៉ោងជាងហ្នឹង!!បានរៀងឃ្យូរបន្តិចដែរ!! ហើយអញ្ចឹងខ្ញុំសូមជូនពរលោកពូក្នុងក្រុមគ្រួសារហើយនិងកូនគាត់ចេះតែផ្តល់ឲ្យលោកពូឲ្យមានជីវភាពមួយដ៏ល្អប្រសើរលោកពូអញ្ចឹងទៅណាស់!!! ហើយអញ្ចឹងសម្រាប់ការសម្ភាសន៍មួយនេះពួកយើងនឹងដាក់ចូលទៅក្នុងwebsiteថៃរក្សាសំឡេងចូលក្នុងវេបសាយមួយហ្នឹងអញ្ចឹងលោកពូអនុញ្ញាតសម្រាប់ការទាំងអស់ហ្នឹងលោកពូ?

ខៈ អត់អីទេ!!!ព្រោះខ្ញុំគ្មានខុសហើយបង!!

កៈ ចាណាស់ហើយតែអាមួយហ្នឹងគេថតតែជា ប្រវត្តិរបស់លោកពូទេលោកពូណោះ?

ខៈ បាទបាទ។

កៈ ចាអញ្ចឹងអរគុណច្រើនណាស់លោកពូ!!

ខៈ បាទបាទ។

កៈ ចាំ។។។